ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត
# សម្រាប់មត្តេយ្យសិក្សារដ្ឋ

នាយកដ្ឋានអប់រំកុមារតូច
ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៥០៣ អយក.ប្រក

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតឱ្យបោះពុម្ពផ្សព្វផ្សាយកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម០/៦១៣/០១២ចុះថ្ងៃទី២០ខែមិថុនាឆ្នាំ២០១៣ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ ១១១៩ អយក.ប្រក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំ
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី០៩ មីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស
- តាមសំណើរបស់ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យបោះពុម្ពផ្សព្វផ្សាយ **កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ** ដែលរៀបចំដោយក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ ដើម្បីប្រើប្រាស់នៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ។

**ប្រការ២ .-**

កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋនេះ មានមាតិកាសំខាន់ៗរួមមាន៖

១-សេចក្តីផ្តើម

២-គោលបំណង

៣-គោលដៅរួមនៃការសិក្សា

៤-របាយម៉ោងសិក្សា

៥-ការណែនាំអនុវត្ត

៦-ការពិនិត្យតាមដាន និងវាយតម្លៃ

៧-តារាងកម្មវិធីសិក្សា

- មត្តេយ្យសិក្សាកម្រិតទាប (កុមារអាយុ ៣ឆ្នាំ)
- មត្តេយ្យសិក្សាកម្រិតមធ្យម (កុមារអាយុ ៤ឆ្នាំ)
- មត្តេយ្យសិក្សាកម្រិតខ្ពស់ (កុមារអាយុ ៥ឆ្នាំ)

ខ្លឹមសារលម្អិតនៃឯកសារកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយសិក្សារដ្ឋ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានអប់រំកុមារតូច ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានធានាគុណភាពអប់រំនិងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ[illegible] ឆ្នាំ២០១៨

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួង អយក

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៣

"ដើម្បីអនុវត្ត"

- ឯកសារកាលប្បវត្តិ

# មុខកថា

កំណែទម្រង់ និងការអភិវឌ្ឍកម្មវិធីសិក្សា ជានិន្នាការមួយស្របទៅនឹងការវិវត្តយ៉ាងលឿនក្នុងបរិបទដែលពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស ។ ទស្សនវិជ្ជាថ្មីមានទំនោរកំណត់បញ្ចូល លទ្ធផលសិក្សាជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សា បានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈ គោលគំនិតគរុកោសល្យ និងវិធីសាស្ត្រសម័យមុន ដោយប្រែក្លាយពីការបង្រៀនមកជាការរៀន ដោយប្រកាន់យកសកម្មភាពសិស្សជាគោល(សិស្សមជ្ឈមណ្ឌល)ពីការផ្ទេរពុទ្ធិមកជាការស្ថាបនាពុទ្ធិដោយខ្លួនឯង ឬសិស្សអាចសម្រេចលទ្ធផលសិក្សាតាមវិធីសាស្ត្រចម្រុះ និងអភិវឌ្ឍបំណិន និងសមត្ថភាពសិស្ស ដើម្បីបណ្តុះគំនិតកុមារឱ្យស្រឡាញ់ការសិក្សាពេញមួយជីវិត ព្រមទាំងធានាបាននូវគុណភាពអប់រំ ក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ការសិក្សាពេញមួយជីវិតគឺជាការផ្តើមចេញពីការធានាឱ្យបាននូវប្រសិទ្ធភាពនៃការចាប់ផ្តើមដំបូងនៃជីវិតសិក្សាពីកម្រិតមត្តេយ្យសិក្សាឡើងទៅ។ ក្រសួងអប់រំ យុវជន និងកីឡា បានកែលម្អកម្មវិធីសិក្សាសំដៅពង្រឹងការកសាងធនធានមនុស្សប្រកបដោយសក្តានុពលក្នុងគោលដៅឆ្ពោះទៅកាន់**សង្គមពុទ្ធិ** និង**វិបុលភាព** កម្លាំងពលកម្មដែលមានចំណេះដឹង ជំនាញវិជ្ជាជីវៈ មានវប្បធម៌ជ្រៅជ្រះ មានផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលភាវូបនីយកម្មដោយឆ្លើយតបយ៉ាងសមស្រប និងទាន់ពេលវេលាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសេចក្តីត្រូវការរបស់ប្រទេសជាតិ ជាពិសេសក្នុងពេលដែលកម្ពុជាបានកំណត់ចក្ខុវិស័យ ប្រែក្លាយពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្ន និងទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ ខាងមុខ។

ឈរលើទស្សនៈខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែលម្អកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សាឱ្យមានលក្ខណៈផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សានៅបឋមសិក្សាចំណេះទូទៅ។

កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សានេះ បានបណ្តុះសញ្ញាណ ឧបនិស្ស័យ បុគ្គលិកលក្ខណៈ និងបំណិនសតវត្សរ៍ទី២១ ដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋពេញលេញនៅពេលអនាគត។ ក្នុងន័យនេះ ពួកគេនឹងទទួលបានពេញលេញនូវសុខុមាលភាពរូបរាងកាយ និងផ្លូវចិត្ត ស្មារតី សាមគ្គីភាព ភាពម្ចាស់ការ ការទទួលខុសត្រូវ សមត្ថភាពពិចារណា ដោះស្រាយបញ្ហា បំណិនអន្តរកម្មបុគ្គល និងសង្គមស្មារតីស្រឡាញ់បរិស្ថាន និងការចូលរួម ។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារ ឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដានវាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា អង្គភាព និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃ អង្គារ [illegible] ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**



**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា ឱ្យទាន់ការអភិវឌ្ឍនៃប្រទេសជាតិ ការរីកចម្រើនរបស់ប្រទេសនានាក្នុងតំបន់ និងសកលលោក ក្រសួងអប់រំ យុវជន និងកីឡា បានកែទម្រង់កម្មវិធីសិក្សាជាបន្តបន្ទាប់ ជាពិសេសក្រសួងបានអភិវឌ្ឍន៍ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស សម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាអប់រំចំណេះទូទៅគ្រប់ភូមិសិក្សា។ ដូចនេះការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាគឺជាការចាំបាច់ ដើម្បីផ្តល់លទ្ធភាពឱ្យកុមារទទួលបានពេញលេញនូវសុខុមាលភាពរាងកាយ និងផ្លូវចិត្ត ស្មារតីសាមគ្គីភាព ភាពម្ចាស់ការ ការទទួលខុសត្រូវសមត្ថភាពពិចារណា ការដោះស្រាយបញ្ហា បំណិនអន្តរកម្មបុគ្គល និងសង្គម ស្មារតី ស្រឡាញ់បរិស្ថាន និងការចូលរួមរបស់កុមារ។ ខ្លឹមសារ និងបំណិនទាំងអស់នេះ នឹងបង្ហាញឱ្យឃើញតាមរយៈការដាក់បញ្ចូលទៅក្នុងមុខវិជ្ជាទាំង៥ គឺមុខវិជ្ជាចិត្តចលភាព បុរេគណិត ភាសាខ្មែរ សិក្សាសង្គម និងវិទ្យាសាស្ត្រ។

ឯកសារនេះ បង្ហាញពីផ្នែកសំខាន់ៗដូចជា សេចក្តីផ្តើម គោលបំណង គោលដៅរួមនៃការសិក្សា របាយម៉ោងសិក្សា ការណែនាំអនុវត្តនូវគោលការណ៍គ្រឹះការអនុវត្ត ការពិនិត្យតាមដាននិងវាយតម្លៃ តារាងកម្មវិធីសិក្សាលទ្ធផលសិក្សាតាមកម្រិតថ្នាក់ (មត្តេយ្យសិក្សាកម្រិតទាប មត្តេយ្យសិក្សាកម្រិតមធ្យម មត្តេយ្យសិក្សាកម្រិតខ្ពស់) រួមនិងផ្នែកសំខាន់ៗមួយចំនួនទៀតដើម្បីបង្កភាពងាយស្រួលក្នុងការរៀបចំធនធាននិងយន្តការអនុវត្តនានាប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

គណៈកម្មការនិពន្ធសង្ឃឹមថា កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋនេះ នឹងបានជាគោលលំអានសម្រាប់ការរៀបចំសៀវភៅណែនាំគ្រូមត្តេយ្យសិក្សា ការតាមដាន និងការវាយតម្លៃលើការផលិតសម្ភារឧបទេសការអនុវត្តវិធីសាស្ត្របង្រៀន និងយន្តការនានាក្នុងការអភិវឌ្ឍកុមារតូច ជាពិសេសការចូលរួមសហការអនុវត្តប្រកបដោយសុឆន្ទៈពីលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ ដៃគូអភិវឌ្ឍន៍ និងគ្រប់សមាសភាពភាគីពាក់ព័ន្ធដទៃទៀត ដើម្បីលើកកម្ពស់ការអប់រំនៅកម្ពុជា ឱ្យមានការអភិវឌ្ឍដូចប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

**គណៈកម្មការនិពន្ធកម្មវិធីសិក្សា**

# មាតិកា


**ប្រកាស** ........................................ i

**បុព្វកថា** ........................................ iii

**អារម្ភកថា**........................................ iv

**មាតិកា** ........................................ v

**១- សេចក្តីផ្តើម**........................................ ១

**២- គោលបំណង**........................................ ២

**៣- គោលដៅរួមនៃការសិក្សា** ........................................ ២

**៤- របាយម៉ោងសិក្សា**........................................ ៤

**៥- ការណែនាំអនុវត្ត** ........................................ ៥

**៦- ការវាយតម្លៃ** ........................................ ៦

**៧- តារាងកម្មវិធីសិក្សា**........................................ ៨

៧.១- កម្មវិធីសិក្សាលម្អិតមត្តេយ្យសិក្សាកម្រិតទាប(កុមារអាយុ ៣ឆ្នាំ)........................................៨

៧.២- កម្មវិធីសិក្សាលម្អិតមត្តេយ្យសិក្សាកម្រិតមធ្យម(កុមារអាយុ ៤ឆ្នាំ)........................................២៣

៧.៣- កម្មវិធីសិក្សាលម្អិតមត្តេយ្យសិក្សាកម្រិតខ្ពស់(កុមារអាយុ ៥ឆ្នាំ)........................................៤០

**៨- ឯកសារយោង** ........................................៥៩

**៩- បញ្ជីឈ្មោះគណៈកម្មការ** ........................................៦០

# ១- សេចក្តីផ្តើម

ការអប់រំចាប់ផ្តើមពីកុមារតូច ជាការអប់រំដែលមានសារៈសំខាន់បំផុត ក្នុងការបណ្តុះស្មារតីជាមូលដ្ឋាន នៃការបង្កើតចរិតលក្ខណៈមនុស្សពេញលេញ។ ការបណ្តុះសញ្ញាណបំណិនសិក្សាពេញមួយជីវិត បង្កើតបរិស្ថានសិក្សារួម និងមធ្យោបាយមានប្រសិទ្ធភាពជាច្រើន នឹងធ្វើឱ្យសម្រេចបាននូវគោលដៅរួមនៃលទ្ធផលសិក្សា របស់កុមារ។ សេវាអប់រំកុមារតូចរួមមានមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សា ឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ(កម្មវិធីអប់រំមាតាបិតា) បានទទួលកុមារអាយុ ៣ឆ្នាំ បាន ២១.៨០% កុមារអាយុ ៤ឆ្នាំបាន ៣៩.៩០% និងកុមារអាយុ ៥ឆ្នាំបាន ៦៨.៥០% នៅឆ្នាំសិក្សា២០១៧-២០១៨ ។

ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ដល់ការសិក្សានៅមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសហគមន៍ ជាពិសេសនៅតំបន់ជួបការលំបាក។កម្មវិធីសិក្សានៅមត្តេយ្យសិក្សាត្រូវបានកែលម្អឡើងវិញនៅឆ្នាំ២០០៧ ដោយបានរៀបចំតម្រូវតាមស្តង់ដាអភិវឌ្ឍការសិក្សារបស់កុមារតូចដែលមាន៥ផ្នែកសំខាន់ៗគឺការអភិវឌ្ឍផ្នែករាងកាយ និងសុខភាព ការអភិវឌ្ឍផ្នែកសីលធម៌ និងវប្បធម៌ ការអភិវឌ្ឍផ្នែកចិត្តសង្គមនិងអារម្មណ៍ ការអភិវឌ្ឍផ្នែកពិចារណានិងការយល់ដឹង និងការអភិវឌ្ឍផ្នែកភាសា។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលបានឯកភាពគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១៩ ខែកុម្ភៈឆ្នាំ២០១០ ព្រមទាំងបានឯកភាពរៀបចំយន្តការអន្តរក្រសួងក្នុងការអនុវត្តគោលនយោបាយជាតិផងដែរ។

ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព(SDG-4) " ធានាការអប់រំបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា "ជាពិសេសក្នុងចំណុចដៅ ៤.២ បានកំណត់ត្រឹមឆ្នាំ២០៣០ ធានាថាកុមារទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដើម្បីពួកគេបានត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា។

ឆ្លើយតបនឹងចំណុចដៅខាងលើនេះ រាជរដ្ឋាភិបាលអាណត្តិទី ៥ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនការកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ ក្នុងនោះក្របខ័ណ្ឌកម្មវិធីសិក្សាថ្មីមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៦ ដោយបានដាក់បញ្ចូលការអប់រំនៅមត្តេយ្យសិក្សាផងដែរ។ ដើម្បីផ្សារភ្ជាប់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាទៅនឹងការអប់រំនៅបឋមសិក្សា ក្របខ័ណ្ឌកម្មវិធីសិក្សាថ្មីនេះ បានសម្រួលខ្លឹមសារកម្មវិធីសិក្សាដែលកំពុងអនុវត្ត១០មុខវិជ្ជាមកជា ៥ មុខវិជ្ជាវិញគឺ ចិត្តចលភាព បុរេគណិត ភាសាខ្មែរ វិទ្យាសាស្ត្រ និងសិក្សាសង្គម។

## ២- គោលបំណង

ដើម្បីធានាបានការអប់រំប្រកបដោយបរិយាបន្ន សមធម៌គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ជាពិសេសក្នុងកំណត់ចំណុចដៅត្រឹមឆ្នាំ ២០៣០ ធានាថាកុមារទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដើម្បីពួកគេបានត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា។ កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាមានគោលបំណងរួម ៖

### ២.១- វិជ្ជាសម្បទា

- ស្គាល់ ចំណាំ ថាតាម ហៅឈ្មោះ និងអានបានតួអក្សរ ពាក្យ ឃ្លា និងល្បះងាយៗដែលធ្លាប់ប្រើប្រាស់ប្រចាំថ្ងៃញឹកញាប់
- ចំណាំ គូសតាម ហៅឈ្មោះ រាប់ចំនួនលេខពីរខ្ទង់ និងស្គាល់រូបរាង ទំហំវត្ថុនានា និងរង្វាស់រង្វាល់មួយចំនួន
- ប្រាប់បានពីរបៀបថែទាំសុខភាពងាយៗ ដូចជាការធ្វើចលនារូបរាងកាយ អនាម័យខ្លួនប្រាណ និងការបរិភោគចំណីអាហារ
- ប្រាប់ពីរបៀបបង្ការខ្លួនពីគ្រោះថ្នាក់ដោយចៃដន្យ ឬដោយធម្មជាតិ ... ។

### ២.២- បំណិនសម្បទា

- ប្រើប្រាស់ភាសាខ្មែរសម្រាប់ទំនាក់ទំនងប្រចាំថ្ងៃក្នុងគ្រួសារ និងសហគមន៍ ដូចជាការស្ដាប់ និយាយ និងប្រើសម្ដីសមរម្យប្រកបដោយការទទួលខុសត្រូវ
- ប្រើប្រាស់គណិតវិទ្យាដូចជា ចំណាំ រាប់ គូសតាម និងប្រៀបធៀប
- រក្សាអនាម័យខ្លួនប្រាណ ការប្រើប្រាស់ចលករតូច ចលករធំ។

### ២.៣- ចរិយាសម្បទា

- សប្បាយរីករាយចូលរួមលេងល្បែងសិក្សា រាងវៃ ក្លាហាន ស្វាហាប់ សកម្ម ចែករំលែក និងសហការ
- ស្រឡាញ់ខ្លួនឯង គ្រួសារ មិត្តភក្ដិ លោកគ្រូ អ្នកគ្រូ និងជនរួមជាតិ
- ស្រឡាញ់បរិស្ថាន វប្បធម៌ និងប្រពៃណីទំនៀមទម្លាប់របស់ជាតិខ្លួន។

## ៣- គោលដៅរួមនៃការសិក្សា

ការសិក្សារៀនសូត្ររបស់កុមារ បានចាប់ផ្ដើមឡើងពីការប្រើប្រាស់ញាណ និងចិត្តចលភាព តាមរយៈការលេង និងសកម្មភាពដោយផ្ទាល់របស់កុមារ។ ការផ្សារភ្ជាប់ការលេងរបស់កុមារទៅនឹងការច្នៃប្រឌិតតាមរយៈវិធីសាស្ត្រខុសៗគ្នា វានឹងផ្ដល់នូវមូលដ្ឋានចំណេះដឹង និងជំនាញមួយចំនួនដូចជា សមត្ថភាពគិតពិចារណា វិនិច្ឆ័យ ម្ចាស់ការ ការចូលរួម និងសហការ។ សញ្ញាណនៃមុខវិជ្ជាមួយចំនួន ត្រូវបានដាក់បញ្ចូលក្នុងគោលដៅសិក្សានៅមត្តេយ្យសិក្សា ដើម្បីផ្សារភ្ជាប់ចំណេះដឹង និងបំណិនទៅបឋមសិក្សា។ នៅពេលបញ្ចប់មត្តេយ្យសិក្សា កុមារ នឹងមានសមត្ថភាពផ្នែក៖

### ៣.១- ចិត្តចលភាព

- ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក
- ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំតូច និងសាច់ដុំធំ

- ការបង្កើនកម្លាំង និងការប្រយុទ្ធទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព។

### ៣.២- វិទ្យាសាស្ត្រ

- ការស្វែងយល់ដោយការសង្កេត
- ការយល់ដឹងអំពីរាងកាយផ្ទាល់ខ្លួន
- ចំណេះដឹងអំពីសហគមន៍
- ចំណេះដឹងពីនិមិត្តសញ្ញាជាតំណាងឱ្យវត្ថុនានា
- ចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ
- ការទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម
- ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព
- លក្ខណៈវត្ថុគ្មានជីវិត និងសត្វមានជីវិត
- ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា
- ការយល់ដឹងពីហេតុនិងផលដែលទាក់ទងលក្ខណៈមេឃ អាកាសធាតុ និងបាតុភូតធម្មជាតិ
- លក្ខណៈរូបធាតុរបស់មនុស្ស សត្វ រុក្ខជាតិ អាកាសធាតុ និងវត្ថុផ្សេងៗ។

### ៣.៣- សិក្សាសង្គម

- ការលើកតម្កើងវប្បធម៌របស់ខ្លួន
- ការស្គាល់អត្តសញ្ញាណរបស់ខ្លួន
- ការយល់ដឹងពីតម្លៃ និងចរិតលក្ខណៈមនុស្ស
- ការពេញចិត្តចំពោះលក្ខណៈផ្សេងៗគ្នារបស់អ្នកដទៃ
- បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងល្អជាមួយមនុស្សជុំវិញ
- បំណិនក្នុងការគិត និងដោះស្រាយរាល់បញ្ហា
- ការយល់ដឹងអំពីទង្វើ និងលទ្ធផល
- ការយល់ដឹងពីអារម្មណ៍ខ្លួនឯង និងអ្នកដទៃ
- ការចេះទប់អារម្មណ៍ និងសម្តែងអារម្មណ៍ល្អៗ
- ការយល់ដឹងអំពីបរិស្ថានធម្មជាតិ និងវិធីការពារ
- ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព
- ចំណេះដឹងបច្ចេកទេស ចលនា  ការច្នៃប្រឌិត និងបទពិសោធន៍ផ្នែកតន្ត្រី។

### ៣.៤- មុនគណិត

- ការយល់អំពីលេខតាង រាប់ចំនួន និងការគណនាលេខសាមញ្ញៗ
- ការស្គាល់បញ្ញត្តិស្តីពីរង្វាស់រង្វាល់
- ការស្គាល់បញ្ញត្តិនៃរូបរាងធរណីមាត្រ លំហ និងទំហំ
- ការធ្វើចំណាត់ក្រុម និងលំដាប់លំដោយ
- ចំណេះដឹងពីការប្រើប្រាស់រូបិយប័ណ្ណជាតិ
- ចំណេះដឹងក្នុងព្រឹត្តិការណ៍ដែលកើតឡើងក្នុងអតីតកាល  បច្ចុប្បន្នកាល និងអនាគតកាល។

### ៣.៥- ភាសាខ្មែរ

- សមត្ថភាពស្តាប់គេនិយាយ និងធ្វើតាមការណែនាំងាយៗ
- ការសន្ទនាដោយប្រើពាក្យ ឬឃ្លាសមស្រប
- ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ
- ទំនាក់ទំនងដោយប្រើពាក្យសម្ដី កាយវិការ និងនិមិត្តសញ្ញា
- ការយល់ដឹងពីភាពខុសគ្នានៃសូរសំឡេង
- ការយល់ដឹងអំពីបញ្ញត្តិនៃសំណេរ
- ការយល់ដឹងអំពីការប្រើប្រាស់ឯកសារសំណេរ / ឯកសារគោលផ្សេងៗ
- ការពេញចិត្ត និងភាពរីករាយជាមួយអំណានដំបូង
- ការយល់ដឹងអំពីគោលការណ៍អក្ខរក្រម
- ការយល់ដឹងពីបែបបទនៃការសូត្រកំណាព្យងាយៗ
- ការបំពេញរូបគំនូរ ឬអក្សរតាមការគូស ផាត់ ពោយ...
- ការយល់ដឹងពីភាសាដទៃទៀត។

## ៤- របាយម៉ោងសិក្សា

កម្មវិធីសិក្សាត្រូវបានកំណត់ឱ្យបង្រៀនចំនួន ៣៥ សប្ដាហ៍ក្នុងមួយឆ្នាំសិក្សា ដោយក្នុងមួយសប្ដាហ៍សិក្សា ៥ ថ្ងៃ ក្នុងមួយថ្ងៃមាន ៦ ម៉ោងសិក្សា និងមួយម៉ោងសិក្សាមានរយៈពេល ៣០នាទី។

### ៤.១- តារាងបែងចែកម៉ោងសិក្សា

| ល.រ. | មុខវិជ្ជា | មត្តេយ្យសិក្សា | | |
|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ |
| ១ | ចិត្តចលភាព | ៦ | ៦ | ៦ |
| ២ | បុរេគណិត | ៣ | ៣ | ៣ |
| ៣ | ភាសាខ្មែរ | ៤ | ៤ | ៤ |
| ៤ | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ |
| ៥ | សិក្សាសង្គម | ១៤ | ១៤ | ១៤ |
| សរុបម៉ោងប្រចាំសប្ដាហ៍ | | **៣០** | **៣០** | **៣០** |

### ៤.២- ម៉ោងសរុបប្រចាំឆ្នាំតាមមុខវិជ្ជា

| ល.រ. | មុខវិជ្ជា | ម៉ោងក្នុង១សប្ដាហ៍ | ម៉ោងប្រចាំឆ្នាំ |
|---|---|---|---|
| ១ | ចិត្តចលភាព | ៦ | ៣៥×៦ = ២១០ |
| ២ | បុរេគណិត | ៣ | ៣៥×៣ = ១០៥ |
| ៣ | ភាសាខ្មែរ | ៤ | ៣៥×៤ = ១៤០ |

| | | | |
|---|---|---|---|
| ៤ | វិទ្យាសាស្ត្រ | ៣ | ៣៥×៣ = ១០៥ |
| ៥ | សិក្សាសង្គម | ១៤ | ៣៥×១៤ = ៤៩០ |
| សរុប | | **៣០** | **១ ០៥០** |

## ៥- ការណែនាំអនុវត្ត

### ៥.១- គោលការណ៍គ្រឹះ

កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា គឺជាអភិក្រមសមស្របតាមការអភិវឌ្ឍ ដែលគិតគូរពីការលើកកម្ពស់ការរៀនសូត្រដ៏សកម្ម ការប្រើប្រាស់មជ្ឈដ្ឋានសិក្សា ការរៀបចំផែនការ និងការពិនិត្យឡើងវិញព្រមទាំងបង្កលក្ខណៈឱ្យកុមារអភិវឌ្ឍទៅតាមភាពសមស្របតាមតម្រូវការពិសេស និងដោយឡែករបស់ពួកគេ។

កម្មវិធីសិក្សានេះរៀបចំឡើង ឈរលើគោលការណ៍សំខាន់ៗក្នុងក្របខ័ណ្ឌកម្មវិធីសិក្សា គឺអភិវឌ្ឍន៍ផ្នែកកាយសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការអភិវឌ្ឍចំណេះដឹង និងជំនាញ ជាចំណុចចាប់ផ្តើមនៃការទទួលយករបស់កុមារមុននឹងមានការប្រែប្រួលផ្នែកកាយសម្បទា និងចរិយាសម្បទា។ បំណិនជាច្រើនរបស់កុមារ ដូចជាបំណិនដោះស្រាយបញ្ហាអន្តរបុគ្គល ទំនាក់ទំនង និងបរិស្ថានជាដើម ត្រូវបានដាក់បញ្ចូលសមស្របតាមការអភិវឌ្ឍរូបរាងកាយ អាយុ និងវប្បធម៌របស់កុមារ។

កម្មវិធីសិក្សានេះបានបំផុសគំនិតច្នៃប្រឌិត ការប្រើប្រាស់សម្ភារឧបទេស សម្ភាររូបវ័ន្ត ប្រើប្រាស់ពេលវេលាសិក្សា និងការណែនាំក្នុងការរៀន និងបង្រៀន ដើម្បីធ្វើឱ្យសម្រេចគោលដៅសិក្សាប្រកបដោយគុណភាព។

គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ ក្នុងសកម្មភាពរៀន និងបង្រៀន ដោយសម្របសម្រួល លើកទឹកចិត្តប្រើប្រាស់សម្ភារៈសមស្រប ជំរុញការរៀនសូត្ររបស់កុមារឱ្យមានភាពរស់រវើក និងសម្រេចគោលដៅសិក្សាស្របតាម អាយុរបស់កុមារ។

ការរៀបចំបរិស្ថានសាលារៀន ថ្នាក់រៀន ផែនការបង្រៀន ការតាមដានការរៀនសូត្ររបស់កុមារ និងយន្តការនានាដើម្បីពង្រឹងប្រសិទ្ធភាពការងារ ក៏ជាគោលដៅសំខាន់ក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សានេះផងដែរ។

គោលការណ៍គ្រឹះដើម្បីអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាមាន ៖

១- ការរៀននិងបង្រៀនត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល និងគោលវិធីចម្រុះ

២- ការសិក្សារបស់កុមារត្រូវធ្វើឡើងតាមការលេង និងសហការ

៣- កុមារត្រូវបានផ្តល់ទំនុកចិត្ត ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការរៀនសូត្រប្រកបដោយឦសុវត្ថិភាព និងភាពកក់ក្តៅ

៤- អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាព កុមារនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបថថ្មីៗបន្ថែមទៀតពីបរិស្ថានសិក្សារបស់ខ្លួន

៥- កុមារជាអ្នកកសាងសមត្ថភាពដោយខ្លួនឯង គ្រូជាអ្នកណែនាំ និងសម្របសម្រួល ដើម្បីឱ្យកុមាររៀនសូត្របានល្អប្រសើរ

៦- ការរៀបចំកិច្ចតែងការបង្រៀន ត្រូវធ្វើតាមគោលវិធីចម្រុះ

៧- បង្កើតយន្តការតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព

៨- ការបង្រៀន និងរៀនត្រូវដំណើរការស្របតាមអាយុ វប្បធម៌ និងសមធម៌

៩- ការរៀន និងបង្រៀនត្រូវមានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ

១០-សាលារៀន និងគ្រូបង្រៀនត្រូវធ្វើអន្តរកម្មជាមួយអ្នកអាណាព្យាបាល សហគមន៍ និងរដ្ឋអំណាច

ដើម្បីធានាគុណភាព និងប្រសិទ្ធភាព។

### ៥.២- ការអនុវត្ត

ដើម្បីអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សានេះ ប្រកបដោយគុណភាព និងប្រសិទ្ធភាព អ្នកអនុវត្តគ្រប់ លំដាប់ថ្នាក់ ត្រូវរៀបចំធនធាន និងយន្តការមួយចំនួនដូចជា ៖

១- អភិវឌ្ឍសៀវភៅណែនាំការបង្រៀនសម្រាប់គ្រូតាមមុខវិជ្ជាស្របតាមកម្រិតនៃក្របខ័ណ្ឌកម្មវិធីសិក្សា ចំណេះទូទៅ និងបច្ចេកទេស

២- អភិវឌ្ឍសម្ភារៈបម្រើឱ្យការរៀន និងបង្រៀន ឯកសារណែនាំប្រើប្រាស់សាមញ្ញ និងងាយស្រួលក្នុងការអនុវត្ត

៣- អភិវឌ្ឍឯកសារជំនួយ និងអំណានបន្ថែមដទៃទៀត ( ល្បែងសិក្សា ពាក្យបណ្តៅ ផ្ទាំងរូបភាព រឿងនិទានងាយៗ ... ) ដើម្បីជួយពង្រឹងការរៀន និងបង្រៀន

៤- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងឯកជនត្រូវរៀបចំជាបន្ទប់ ឬជ្រុងថ្នាក់រៀនសម្រាប់លេង អានសៀវភៅ សម្តែង តន្ត្រី ទុកដាក់សម្ភារៈ និទានរឿង ...

៥- គ្រឹះស្ថានមត្តេយ្យសិក្សា ត្រូវរៀបចំទីធ្លាប្រកបដោយបរិស្ថានល្អ មានសុវត្ថិភាព សម្រាប់ដំណើរការលេង កម្សាន្ត ល្បែង និងលំហាត់ប្រាណជាដើម

៦- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវរៀបចំផែនការបង្រៀនប្រចាំឆ្នាំ ប្រចាំខែ ប្រចាំសប្តាហ៍ និង ប្រចាំថ្ងៃ ស្របតាមពេលវេលា និងកម្មវិធីសិក្សាដែលបានកំណត់

៧- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនីមួយៗ ត្រូវរៀបចំយន្តការ និងឯកសារផ្សេងៗ ដើម្បីធ្វើអន្តរកម្ម មានប្រសិទ្ធភាពរវាងសាលារៀន មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍

៨- គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនតាមម៉ោងកំណត់ស្របតាមការណែនាំ និងខ្លឹមសារកម្មវិធីសិក្សា

៩- រៀបចំធនធានា និងយន្តការថ្មីៗផ្សេងទៀត ដើម្បីពង្រឹងការអនុវត្តការអប់រំកុមារមត្តេយ្យសិក្សានៅកម្ពុជា ប្រកបដោយការទទួលខុសត្រូវ ។

## ៦- ការវាយតម្លៃ

ជាទូទៅការតាមដាន និងវាយតម្លៃមានច្រើនបែប ច្រើនយ៉ាង និងមានគោលបំណងផ្សេងៗគ្នា។ ប៉ុន្តែជារួម ការពិនិត្យតាមដាន និងវាយតម្លៃមានគោលបំណងដូចតទៅ ៖

- វាស់កម្រិតចំណេះដឹង បំណិន ឬសមត្ថភាពរបស់កុមារមុនចាប់ផ្តើមសិក្សា និងក្រោយពីបានសិក្សាចប់ មេរៀន ជំពូក ប្រធានបទ ឬកម្មវិធីសិក្សាតាមកម្រិតថ្នាក់ តាមមុខវិជ្ជា
- វាស់កម្រិតនៃការប្រែប្រួល ឬការរីកចម្រើនផ្លូវចិត្ត និងគុណតម្លៃនានា ដូចជាតម្លៃសីលធម៌ ឥរិយាបថ សាមគ្គីភាព ព្រហ្មវិហារធម៌ ។ល។
- ឆ្លុះបញ្ចាំងពីលទ្ធផលនៃការរៀន និងបង្រៀនដោយផ្តល់ព័ត៌មានត្រឡប់ក្នុងការជួយគ្រូ កុមារ មាតាបិតា ឬអ្នកអាណាព្យាបាលកុមារ និងគណៈគ្រប់គ្រងដើម្បីលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន ឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់។

សម្រាប់ការតាមដាន និងវាយតម្លៃនៅមត្តេយ្យសិក្សា មានលក្ខណៈពិសេសដោយឡែក អំពីវិធីវាយតម្លៃ

សម្រាប់កុមារនៅបឋមសិក្សា និងមធ្យមសិក្សា។ គ្រូមានតួនាទីយ៉ាងសំខាន់ក្នុងការសង្កេតតាមដាន និងវាយតម្លៃការរីកចម្រើនរបស់កុមារតាំងពីកាយ វាចា ចិត្ត ឥរិយាបថ និងការចូលរួមរបស់កុមារ។ ការតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់កុមារ គួរមានបីដំណាក់កាលដូចតទៅ ៖

### ៦.១- ការស្តាប់ និងសង្កេតមើលកុមារ

ការស្តាប់ និងសង្កេតមើលដំណើរការលេង និងការរៀនសូត្ររបស់កុមារ ជាដំណើរការដំបូងៗនៃការឈ្វេងយល់ទៅលើចិត្តគំនិត ឥរិយាបថ និងការយល់ដឹងរបស់កុមារដោយៈ

- កំណត់ចំណុចដែលត្រូវសង្កេត និងតាមដានជាស្រេច
- សង្កេត ស្តាប់ តាមដានត្រួសៗក្រៅផ្លូវការ
- សង្កេត តាមដានជាផ្លូវការ គួរធ្វើឡើងជាលក្ខណៈបុគ្គល ជាដៃគូ និងជាក្រុម
- ប្រើតារាងដែលបង្ហាញពីការអភិវឌ្ឍរបស់កុមារលើចំណុចដែលបានកំណត់
- ធ្វើកំណត់ហេតុនៃការតាមដានដោយជាក់លាក់ និងសត្យានុម័ត
- ផ្តល់ព័ត៌មានត្រឡប់ជាក់លាក់ដល់អ្នកពាក់ព័ន្ធ។

### ៦.២- ជំរុញ និងផ្តល់ការណែនាំបន្ថែម

បន្ទាប់ពីទទួលបានព័ត៌មានជាក់លាក់ពីកុមារ ទៅតាមលទ្ធផលនៃការសង្កេតតាមដានរួចហើយ គ្រូ ឬអ្នកពាក់ព័ន្ធគប្បីៈ

- រៀបចំ និងលើកផែនការសកម្មភាពដើម្បីជួយជំរុញដល់កុមារណាដែលខ្សោយ
- ជំរុញ និងលើកទឹកចិត្តកុមារទៅតាមចំណេះដឹង ទេពកោសល្យ និងការអភិវឌ្ឍរបស់កុមារដោយបង្កលក្ខណៈ និងបរិយាកាសសិក្សា ដើម្បីធ្វើឱ្យសម្រេចបានលទ្ធផលល្អទៅលើចំណុចខ្វះខាតដែលបានរកឃើញ
- ធ្វើអន្តរកម្មជាមួយកុមារឱ្យកាន់តែប្រសើរ និងប្រើប្រាស់គ្រប់មធ្យោបាយ និងធនធានដើម្បីឱ្យកុមារចាប់យកចំណេះដឹង និងបំណិនទៅតាមគោលការណ៍កំណត់
- លើកទឹកចិត្តឱ្យកុមារទទួលបានចំណេះដឹង និងបំណិនថ្មីៗថែមទៀតទៅតាមចំណង់ចំណូល ចិត្ត ទេពកោសល្យ និងមុខវិជ្ជាសិក្សា។

### ៦.៣- ការវាយតម្លៃលទ្ធផលសិក្សារបស់កុមារជាផ្លូវការ

ដំណាក់កាលនេះ ជាដំណាក់បញ្ជាក់ចុងក្រោយពីលទ្ធផលនៃការប្រែប្រួល និងការអភិវឌ្ឍរបស់កុមារ ទៅលើគោលដៅសិក្សាដែលបានកំណត់ដោយៈ

- ប្រមូលអង្គហេតុដែលបញ្ជាក់ដោយកិច្ចការរបស់កុមារ
- វិភាគ និងវាយតម្លៃព័ត៌មានដែលទទួលបាន
- ប្រៀបធៀបលទ្ធផលជាមួយបញ្ជីក្នុងតារាងត្រួតពិនិត្យដែលបានតាមដាន
- ឆ្លុះបញ្ចាំងទៅលើការសិក្សារៀនសូត្ររបស់កុមារ ការអនុវត្តរបស់គ្រូ សាលារៀន ធនធាន បរិស្ថានសិក្សា និងយន្តការនានាក្នុងដំណើរការរៀន និងបង្រៀន
- រកវិធានការនានាដែលមានគុណភាព និងប្រសិទ្ធភាពដើម្បីអនុវត្តបន្តប្រកបដោយទំនុកចិត្ត។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាកម្រិតទាប(កុមារអាយុ៣ឆ្នាំ)

### មុខវិជ្ជា ៖ ចិត្តចលភាព (២១០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **បំណិនចលករតូច** | ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។<br>**បំណិនសម្បទា**<br>- កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែក ឬលេងល្បែងបានរឹងមាំ ។<br>**ចរិយាសម្បទា**<br>- មានអំណត់ តស៊ូព្យាយាម និងសប្បាយរីករាយក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ និងជោគជ័យ។ | ៣៥ ម៉ |
| **បំណិនចលករធំ** | ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំតូច និងសាច់ដុំធំ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបដើរ រត់ វារ លូន លោត ចុះ ឡើង បោះឱ្យត្រូវតាមគោលដៅ។<br>**បំណិនសម្បទា**<br>- ដើរទប់ខ្លួនឱ្យមានលំនឹង លើគំនូសខ្សែដោយដៃកាន់វត្ថុនានា<br>- រត់នៅមួយកន្លែង រត់ឃើត រត់លឿន<br>- លោតនៅមួយកន្លែង លោតទៅមុខ លោតថយក្រោយ<br>- ឡើង និងចុះជណ្តើរខ្សែពួរកម្ពស់ ១ម៉ែត្រ និងលើសពីនេះ<br>- វារលូន លើកន្ទេល កម្រាលឥដ្ឋ សំបកកង់<br>- បោះបាល់ដោយដៃទាំងពីរចំនួន៣ដងចូលក្នុងផ្ទាំងក្រដាសរាងការេទំហំ ៣០សម x ៣០សមក្នុងចម្ងាយ ១.៥០ ម៉ែត្រ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយ និងចូលចិត្ត ក្នុងការធ្វើចលនាប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ។ | ៣៥ ម៉ |
| **ការរីកចម្រើនរាងកាយនិងចលនា** | ការបង្កើនកម្លាំងនិងការប្រឈមទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព | **វិជ្ជាសម្បទា**<br>- បង្ហាញពីរបៀបដើរ រត់ លោត ឬលើសពីនេះ ទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។<br>**បំណិនសម្បទា**<br>- អនុវត្តសកម្មភាពមួយបានទន់ភ្លន់ រហ័សរហួន និងរឹងមាំដោយ | ១៤០ ម៉ |

| | | | |
|---|---|---|---|
| | | ការផ្តើមចេញពីចលនាមូលដ្ឋានងាយៗទៅលំបាកចាប់ពីចំនួន ២ ឡើងទៅ ក្នុងនោះមានការដើរ រត់ លោត ឬលើសពីនេះ តាមរយៈចលនាចរន្ត ហាត់ប្រាណតាមរឿងនិទាន បទចម្រៀង បទភ្លេង និងល្បែងចលនា។<br>**ចរិយាសម្បទា**<br>- ក្លាហាន ជឿជាក់លើសមត្ថភាព និងកម្លាំងរបស់ខ្លួន ថាមានសុវត្ថិភាព ក្នុងពេលធ្វើសកម្មភាពឆ្លងកាត់ឧបសគ្គ ។ | |

## មុខវិជ្ជា ៖ វិទ្យាសាស្ត្រ (១០៥ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **អាហារូបត្ថម្ភ** | ចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះបន្លែ ផ្លែឈើ និងសាច់នានា<br>- ប្រាប់បានអំពីរសជាតិផ្លែឈើ និងសារៈប្រយោជន៍ ។<br>**បំណិនសម្បទា**<br>- បង្ហាញបានឈ្មោះបន្លែ ផ្លែឈើ និងសាច់នានា<br>- បង្ហាញអំពីរសជាតិផ្លែឈើ និងសារៈប្រយោជន៍របស់វា។<br>**ចរិយាសម្បទា**<br>- មានចំណូលចិត្តហូបបន្លែ ផ្លែឈើ និងសាច់ ដែលមានសារៈប្រយោជន៍ចំពោះសុខភាព<br>- ចូលរួមដាំ និងថែរក្សាដំណាំ បន្លែ ផ្លែឈើ។ | ១៥ ម៉ |
| **អនាម័យ** | ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម | **វិជ្ជាសម្បទា**<br>- ប្រាប់ពីទម្លាប់ល្អទាំងឡាយមុន និងក្រោយពេលញ៉ាំអាហារ ផ្លែឈើ ប្រើប្រាស់បង្គន់អនាម័យ និងសម្អាតខ្លួនប្រាណ<br>- ប្រាប់ពីវិធីការពារក្នុងពេលក្អក កណ្តាស់ និងសម្អាតច្រមុះ។<br>**បំណិនសម្បទា**<br>- លាងសម្អាតដៃតាមពេលវេលាដូចជា មុន និងក្រោយពេលញ៉ាំអាហារ ក្រោយពេលចេញពីបង្គន់ជាដើម<br>- ខ្ទប់មាត់នៅពេលក្អក កណ្តាស់ និងសម្អាតច្រមុះពេលហៀរសំបោរ<br>- លាងសម្អាតផ្លែឈើមុនពេលញ៉ាំ<br>- ងូតទឹក ដុសធ្មេញ សិតសក់ និងសម្អាតដៃជើងខ្លួនឯង។<br>**ចរិយាសម្បទា**<br>- ទម្លាប់មានអនាម័យក្នុងការរស់នៅដូចជា មុន និងក្រោយពេលញ៉ាំអាហារ ចូលបង្គន់អនាម័យ និងសម្អាតខ្លួនប្រាណ<br>- ប្រុងប្រយ័ត្នក្នុងពេលក្អក កណ្តាស់ និងសម្អាតច្រមុះ។ | ៩ ម៉ |

| | | | |
|---|---|---|---|
| **ប្រតិបត្តិដោយសុវត្ថិភាព** | ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះឪពុកម្ដាយ ឬអ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់នៅពេលវង្វេងផ្លូវ<br>- ប្រាប់ពីសកម្មភាពមួយចំនួនដែលនាំឱ្យមានគ្រោះថ្នាក់ដូចជាការលេងភ្លើង អគ្គិសនី វត្ថុមុតស្រួច ពាងទឹក និងស្រះទឹក។<br>**បំណិនសម្បទា**<br>- បង្ហាញពីឈ្មោះឪពុកម្ដាយ  អ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់នៅពេលវង្វេងផ្លូវ<br>- រៀបរាប់បានពីគ្រោះថ្នាក់ដែលបណ្ដាលមកពី ការលេងភ្លើង អគ្គិសនី វត្ថុមុតស្រួច ពាងទឹក និងស្រះទឹក ។<br>**ចរិយាសម្បទា**<br>- ក្លាហានមិនតក់ស្លុតក្នុងការប្រាប់ឈ្មោះឪពុកម្ដាយ អ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់ នៅពេលវង្វេងផ្លូវ<br>- ចៀសវាងសកម្មភាពមួយចំនួនដែលនាំឱ្យមានគ្រោះថ្នាក់ដូចជា ការលេងភ្លើង អគ្គិសនី វត្ថុមុតស្រួច និងស្រះទឹក ។ | ១២ ម៉ |
| **ការរស់នៅប្រចាំថ្ងៃ** | ការស្វែងយល់ដោយការសង្កេត | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះសត្វឱ្យបាន២ប្រភេទ ឬលើសពីនេះ<br>- ប្រាប់ពីលក្ខណៈរូបផ្ដុំ ចរិតលក្ខណៈរបស់សត្វ<br>- ប្រាប់បានពីរបៀបប្រៀបធៀបសត្វ។<br>**បំណិនសម្បទា**<br>- រៀបរាប់ឈ្មោះសត្វ ចរិតលក្ខណៈ លក្ខខណ្ឌរស់នៅ ផលប្រយោជន៍ វដ្ដនៃសត្វ និងការប្រៀបធៀបសត្វ ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលចិត្តចិញ្ចឹម និងថែរក្សាសត្វ។ | ១៥ ម៉ |
| | លក្ខណៈរូបធាតុ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវត្ថុដែលធ្វើពីឈើ ដែក ជ័រប្លាស្ទិច និងថ្ម<br>- ប្រាប់ពីភាពខុសគ្នាវត្ថុធាតុដើមនៃសម្ភារៈដោយប្រើបញ្ញត្តិ ដូចជា រឹង ទន់ ក្ដៅ ត្រជាក់ ជាដើម។<br>**បំណិនសម្បទា**<br>- ញែកបានរវាងវត្ថុធ្វើពីឈើ ដែក ជ័រប្លាស្ទិច និងថ្ម<br>- ញែកបានពីភាពខុសគ្នារវាងវត្ថុធាតុដើមនៃសម្ភារៈដោយ ប្រើបញ្ញត្តិដូចជា រឹង ទន់ ក្ដៅ ត្រជាក់ ជាដើម។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វត្ថុដែលបង្កគ្រោះថ្នាក់។ | ១២ ម៉ |

| | | | |
|---|---|---|---|
| | **អំពីរាងកាយផ្ទាល់ខ្លួន** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះផ្នែកផ្សេងៗ និងមុខងារនៃរាងកាយរបស់មនុស្ស ។<br>**បំណិនសម្បទា**<br>- បង្ហាញពីមុខងាររបស់ផ្នែកផ្សេងៗនៃរាងកាយមនុស្សដូចជា ភ្នែកសម្រាប់ មើល ត្រចៀកសម្រាប់ស្តាប់ មាត់សម្រាប់ ញ៉ាំបាយ ឬនិយាយជាដើម។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្ន និងថែរក្សាសុខភាពផ្នែកផ្សេងៗនៃរាងកាយ។ | **៩ ម៉** |
| | **ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗ ដែលប្រើក្នុងជីវភាពប្រចាំថ្ងៃ<br>- ប្រាប់ឈ្មោះសំណង់សាមញ្ញៗ មួយចំនួន។<br>**បំណិនសម្បទា**<br>- រៀបរាប់អំពីឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗ ដែលប្រើក្នុងជីវភាពប្រចាំថ្ងៃដូចជា ទូរទស្សន៍ កង្ហារ ជាដើម<br>- សាងសំណង់សាមញ្ញៗដោយប្រើដីឥដ្ឋ ឬដុំឥដ្ឋឬដុំឈើ។<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយ័ត្នខ្ពស់ក្នុងការប៉ះពាល់ ឬធ្វើសកម្មភាព។ | **៩ ម៉** |
| | **មធ្យោបាយធ្វើដំណើរ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីមធ្យោបាយធ្វើដំណើរផ្លូវគោកចំនួន១ ផ្លូវទឹកចំនួន ១ និងផ្លូវអាកាសចំនួន១។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីឈ្មោះ ទ្រង់ទ្រាយ និងផលប្រយោជន៍បានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលរួមថែរក្សាផលប្រយោជន៍របស់មធ្យោបាយធ្វើដំណើរនីមួយៗ។ | **៦ ម៉** |
| **បំណិនពិចារណា** | **ការយល់ដឹងពីហេតុ និងផល** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីលក្ខណៈអាកាសធាតុ ស្ថានភាពវត្ថុអ្វីមួយ<br>- ប្រាប់បានពីសកម្មភាពដែលជះឥទ្ធិពលលើវត្ថុនានាដូចជា ប្រមៀលបាល់ បាល់នឹងរមៀល។<br>**បំណិនសម្បទា**<br>- ប៉ាន់ស្មានទុកជាមុនអំពីបាតុភូតនានា ដូចជាអាចនឹងមាន ភ្លៀងនៅពេលឃើញមេឃងងឹតជាដើម | **១២ ម៉** |

| | | | |
|---|---|---|---|
| | | - បញ្ជាក់បានពីសកម្មភាពដែលបានជះឥទ្ធិពលលើវត្ថុ ដូចជា ប្រមៀលបាល់ បាល់នឹងរមៀល។<br>**ចរិយាសម្បទា**<br>- មានទម្លាប់គិតពិចារណារកហេតុ និងផលទៅតាមអ្វីដែលបានមើលឃើញ ។ | |
| **បំណិន ក្នុងសង្គម** | ចំណេះដឹងអំពីសហគមន៍ | **វិជ្ជាសម្បទា**<br>- ប្រាប់បានឈ្មោះសាលារៀន កម្រិតថ្នាក់ និងគ្រូបង្រៀន។<br>**បំណិនសម្បទា**<br>- បង្ហាញឈ្មោះសាលារៀន កម្រិតថ្នាក់ និងឈ្មោះគ្រូបង្រៀនបានត្រឹមត្រូវ ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ និងចូលចិត្តសាលារៀនខ្លួន។ | ៦ ម៉ |

## មុខវិជ្ជា ៖ សិក្សាសង្គម (៤៩០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **ការយល់ដឹងពីតម្លៃមនុស្ស** | ការយល់ដឹងពីតម្លៃនិងចរិតលក្ខណៈរបស់មនុស្ស | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីការគួរសមជាមួយមនុស្សជុំវិញខ្លួន(ខ្ញុំ បាទ ចាស អរគុណ សុំទោស ជម្រាបសួរ ជម្រាបលា)<br>- ប្រាប់បានពីអំពើមិនល្អ និងអំពើល្អ (បុណ្យ បាប)។<br>**បំណិនសម្បទា**<br>- គោរព និងប្រើពាក្យគួរសមជាមួយមនុស្សជុំវិញខ្លួន (ខ្ញុំ បាទ ចាស អរគុណ សុំទោស ជម្រាបសួរ ជម្រាបលា)<br>- បែងចែករវាងអំពើមិនល្អ និងអំពើល្អបានច្បាស់លាស់។<br>**ចរិយាសម្បទា**<br>- ជួយគ្នាក្នុងពេលជួបបញ្ហា និងគោរពអ្នកដទៃ<br>- គោរពវេនក្នុងពេលលេងល្បែងដោយមិនបង្កទំនាស់ ។ | ៥ ម៉ |
| **ការលើកតម្កើងវប្បធម៌** | ការលើកតម្កើងវប្បធម៌របស់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះបុណ្យប្រពៃណីជាតិខ្មែរដូចជា បុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ ជាដើម<br>- ប្រាប់បានពីទង់ជាតិរបស់ប្រទេសកម្ពុជា<br>- ប្រាប់បានពីឈ្មោះឧបករណ៍ភ្លេងខ្មែរដូចជា ស្គរ ខ្លុយជាដើម<br>- ប្រាប់បានពីទីកន្លែងសំខាន់ៗដូចជាវត្តអារាម មន្ទីរពេទ្យ...<br>- ប្រាប់បានពីសម្លៀកបំពាក់ប្រពៃណីខ្មែរដូចជា ក្រមា ហូល អាវប៉ាក់ ជាដើម<br>- ច្រៀងបទគោរពទង់ជាតិបាន១វគ្គ(បទនគររាជ) | ២០ ម៉ |

| | | | |
|---|---|---|---|
| | | **បំណិនសម្បទា**<br>- រៀបរាប់បានពីការប្រារព្ធពិធីបុណ្យប្រពៃណីជាតិខ្មែរដូចជាបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ ជាដើម<br>- រៀបរាប់បានពីទីកន្លែងសំខាន់ៗដូចជា វត្តអារាម មន្ទីរពេទ្យ...<br>- កំណត់បានពីសម្លៀកបំពាក់ប្រពៃណីជនជាតិខ្មែរដូចជាក្រមាហូល អាវប៉ាក់ ជាដើម<br>- បង្ហាញបានពីទង់ជាតិប្រទេសកម្ពុជា<br>- ច្រៀងបទគោរពទង់ជាតិបានមួយវគ្គ(បទនគររាជ)<br>- បង្ហាញបានពីឧបករណ៍ភ្លេងខ្មែរដូចជា ស្គរ ខ្លុយជាដើម ។<br>**ចរិយាសម្បទា**<br>- សំពះនៅពេលឃើញព្រះបដិមា ព្រះសង្ឃ និងពេលសូត្រធម៌<br>- ចូលរួមគោរពទង់ជាតិបានទៀងទាត់ដោយសេចក្ដីអត់ធ្មត់ ។ | |
| **បំណិនទំនាក់ទំនង** | អត្តសញ្ញាណរបស់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឈ្មោះខ្លួនឯងទាំងឈ្មោះហៅក្រៅ និងឈ្មោះផ្លូវការ ។<br>**បំណិនសម្បទា**<br>- បង្ហាញឈ្មោះខ្លួនឯងទាំងឈ្មោះហៅក្រៅ និងឈ្មោះផ្លូវការ ។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តក្នុងការប្រាប់ឈ្មោះខ្លួនឯង ទាំងឈ្មោះហៅក្រៅ និងឈ្មោះផ្លូវការ ទៅអ្នកដទៃនៅពេលមានតម្រូវការ ។ | **៥ ម៉** |
| | **បំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះមនុស្សជុំវិញឱ្យជួយនៅពេលមានបញ្ហា<br>- ប្រាប់ពីការងារមួយចំនួនដូចជាការឱ្យចំណីសត្វ ស្រោចដំណាំជាដើម ។<br>**បំណិនសម្បទា**<br>- រៀបរាប់ឈ្មោះមនុស្សជុំវិញដើម្បីឱ្យពួកគេជួយនៅពេលខ្លួនមានបញ្ហា<br>- ជួយការងារមនុស្សធំដូចជាការឱ្យចំណីសត្វ ស្រោចដំណាំ..។<br>**ចរិយាសម្បទា**<br>- បង្ហាញនូវភាពក្លាហាន និងទន់ភ្លន់ក្នុងការធ្វើទំនាក់ទំនង ជាមួយមនុស្សធំនៅពេលមានបញ្ហា<br>- ទម្លាប់ជួយការងារស្រាលៗទៅតាមកម្លាំង ។ | **៥ ម៉** |
| | **បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងល្អជាមួយមិត្តភក្ដិដែលមានវ័យប្រហាក់** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវត្តមាន អវត្តមានរបស់មិត្តភក្ដិ កាលបរិច្ឆេទ...<br>- ប្រាប់ឈ្មោះ និងលក្ខណៈសម្បត្តិកុមារដែលខ្លួនលេងជាមួយ<br>- ប្រាប់ពីរបៀបលេងល្បែងសេរីដែលបានលេងជាមួយមិត្តភក្ដិ | **៣២០ ម៉** |

| | | | |
|---|---|---|---|
| | **ប្រហែលគ្នា** | ឬលេងជាលក្ខណៈបុគ្គល ។<br>**បំណិនសម្បទា**<br>- បង្ហាញពីវត្តមាន អវត្តមានមិត្តភក្តិ កាលបរិច្ឆេទប្រចាំថ្ងៃដោយប្រើតារាងសកម្មភាពប្រចាំថ្ងៃ និងអនុវត្តទម្លាប់ល្អជាប្រចាំ<br>- បង្ហាញពីឈ្មោះ និងលក្ខណៈសម្បត្តិរបស់កុមារដទៃទៀត<br>- លេងល្បែងសេរីដែលខ្លួនចូលចិត្តជាបុគ្គល ឬជាក្រុមបានត្រឹមត្រូវ និងសុខដុម។<br>**ចរិយាសម្បទា**<br>- គោរពពេលវេលាបានទៀងទាត់ និងមានទម្លាប់ល្អ<br>- សប្បាយរីករាយក្នុងការលេងល្បែងជាមួយមិត្តភក្តិ។ | |
| | **ការយល់ដឹងអំពីទង្វើ និងលទ្ធផល** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអំពើដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។<br>**បំណិនសម្បទា**<br>- ធ្វើអំពើទាំងឡាយណាដែលមិនប៉ះពាល់ដល់អ្នកដទៃ។<br>**ចរិយាសម្បទា**<br>- ចៀសវាងទង្វើទាំងឡាយដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។ | **៥ ម៉** |
| | **ការពេញចិត្តចំពោះលក្ខណៈផ្សេងគ្នារបស់បុគ្គល** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីសមត្ថភាពមនុស្សម្នាក់ដែលខ្លួនស្រឡាញ់ចូលចិត្ត។<br>**បំណិនសម្បទា**<br>- វាយតម្លៃបានត្រឹមត្រូវ និងគាំទ្រដោយភាពពេញចិត្តចំពោះសមត្ថភាពរបស់មិត្តភក្តិ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយក្នុងការលេងជាមួយកុមារដទៃទៀតដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ វណ្ណៈ ពិការ។ | **៥ ម៉** |
| **ការយល់ដឹងអំពីខ្លួនឯង** | **ស្គាល់ពីអារម្មណ៍មួយចំនួន** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីអ្វីដែលធ្វើឱ្យកុមារសប្បាយចិត្ត និងមិនសប្បាយចិត្ត។<br>**បំណិនសម្បទា**<br>- បង្ហាញកាយវិការ ឬនិយាយបានអំពីសេចក្តីស្រឡាញ់ និងទំនាក់ទំនងជាមួយមនុស្សដែលនៅជុំវិញ។<br>**ចរិយាសម្បទា**<br>- ទំនាក់ទំនងល្អទាំងកាយវិការ និងសម្តីប្រកបដោយសេចក្តីស្រឡាញ់ជាមួយមនុស្សដែលនៅជុំវិញ ។ | **៥ ម៉** |
| | **សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយធ្វើកាយវិការ។ | **៥ ម៉** |

| | | | |
|---|---|---|---|
| | | **បំណិនសម្បទា**<br>- សម្តែងបានពីអារម្មណ៍ និងធ្វើកាយវិការរបស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្ត<br>- សម្របខ្លួនតាមចិត្តមនុស្សធំនៅពេលចង់បានអ្វីមួយ<br>- ប្រាប់បានពីរបៀបសម្របខ្លួនតាមចិត្តមនុស្សធំនៅពេលចង់បានអ្វីមួយ។<br>**ចរិយាសម្បទា**<br>- ទទួលស្គាល់ភាពជោគជ័យ និងបរាជ័យរបស់ខ្លួន។ | |
| **បំណិនក្នុងសង្គម** | **ការយល់ដឹងអំពីបរិស្ថាន ធម្មជាតិ និងវិធីការពារ** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះទីកន្លែងដែលជាបរិស្ថាន និងទង្វើល្អ ដូចជាការមិនចោលសំរាមផ្តេសផ្តាស ការបំផ្លាញរុក្ខជាតិ ជាដើម។<br>**បំណិនសម្បទា**<br>- ជួយសម្អាតបរិស្ថានដូចជាការបោសសំរាម ដាក់សំរាមក្នុងធុង ថែរក្សារុក្ខជាតិជាដើម<br>- រៀបរាប់ឈ្មោះទីកន្លែងក្នុងបរិស្ថាន។<br>**ចរិយាសម្បទា**<br>- ចូលចិត្តរស់នៅស្អាត និងស្រឡាញ់បរិស្ថាន<br>- ធ្វើការងារដោយប្រុងប្រយ័ត្ន និងមានសុវត្ថិភាព ។ | **៥ ម៉** |
| **គំនូរ និងសកម្មភាពកសាង** | **ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបបត់ក្រដាសជារាងងាយៗបត់ជា ២ ឬ៣ផ្នត់<br>- ប្រាប់បានពីរបៀបសូនរូបជារាងងាយៗដោយប្រើដៃទាំងពីរ<br>- ប្រាប់បានពីរបៀបផាត់ពណ៌តាមរូបគំរូ ។<br>**បំណិនសម្បទា**<br>- បត់ក្រដាសបានជារាងងាយៗ បត់ជា២ផ្នត់ ឬ៣ផ្នត់<br>- សូនរូបបានជារាងងាយៗដោយប្រើដៃទាំងពីរ<br>- បង្ហាញអំពីរបៀបនៃការបត់ក្រដាស ឬសូនរូប ឬផាត់ពណ៌ឱ្យមានសោភ័ណ និងបង្ហាញពីអ្វីដែលបានផាត់រួចហើយ។<br>**ចរិយាសម្បទា**<br>- រហ័សរហួន ប្រុងប្រយ័ត្ន ក្នុងការចាប់បត់ក្រដាសសូនរូប និងផាត់ពណ៌<br>- ស្រឡាញ់ និងចូលចិត្តភាពស្រស់ស្អាត។ | **៣០ ម៉** |

| | | | |
|---|---|---|---|
| | ការយល់ដឹងពីភាពឆ្លាស់នៃវត្ថុតាមចង្វាក់ និងការគូរគំនូរ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវិធីកាន់ខ្មៅដៃ ដីស ឬមែកឈើក្នុងការគូររង្វង់ តូច ធំ គូរសេរី គំនូសផ្សេងៗ និងដោតអង្កាំ ឬវត្ថុមានប្រហោង ។<br>**បំណិនសម្បទា**<br>- ដោតអង្កាំ ឬវត្ថុមានប្រហោងត្រូវតាមបញ្ញត្តិងាយៗ(ដោតអង្កាំធម្មតា ឬឆ្លាស់ពណ៌ស១ ក្រហម១ឱ្យបានខ្សែដៃ១ខ្សែ... )<br>- គូររាងរង្វង់តូច និងធំជារូបភាពងាយៗ<br>- គូសផ្គុំគំនូសមូលដ្ឋានជារាងផ្សេងៗ និងរូបភាពងាយៗ។<br>**ចរិយាសម្បទា**<br>- រីករាយ និងចូលចិត្តធ្វើសកម្មភាពដោយប្រុងប្រយ័ត្ន។ | ៣៥ ម៉ |
| **ចម្រៀង និងតន្ត្រី** | ចំណេះដឹងបច្ចេកទេសចលនា ការច្នៃប្រឌិត និងបទពិសោធន៍ពីតន្ត្រី | **វិជ្ជាសម្បទា**<br>- ប្រាប់ពីបទចម្រៀងដែលបានឮ និងរបៀបធ្វើកាយវិការ<br>- ប្រាប់បានពីរបៀបទះដៃ ឬគោះសម្ភារៈនានាតាមចង្វាក់ភ្លេង<br>- ប្រាប់បានពីរបៀបរាំតាមចង្វាក់ប្រពៃណីខ្មែរ ដូចជា រាំវង់...។<br>**បំណិនសម្បទា**<br>- ច្រៀងចម្រៀង និងធ្វើកាយវិការ តាមខ្លឹមសារបទចម្រៀងបានមួយបទ ឬលើសពីនេះ<br>- ទះដៃបន្ទរ ឬគោះសម្ភារៈនានាត្រូវតាមចង្វាក់ភ្លេង<br>- រាំតាមចង្វាក់ប្រពៃណីខ្មែរ ដូចជា រាំវង់ ជាដើម។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ និងចូលចិត្តបទចម្រៀង និងរបាំប្រពៃណីខ្មែរ។ | ៤៥ ម៉ |

## មុខវិជ្ជា ៖ មុនគណិត (១០៥ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **បរិមាណ និងចំនួន** | ស្គាល់ យល់លេខ គាង ការរាប់ចំនួន និងការគណនាលេខសាមញ្ញៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីចំនួន លេខ និងយល់ន័យពី ១ ដល់ ១០ ឬលើសពីនេះតាមលំដាប់លំដោយ<br>- ប្រាប់ពីសំណុំចំនួនតិចជាង ច្រើនជាង និងស្មើគ្នា<br>- ប្រាប់បានពីរបៀបបន្ថែម និងដកចំនួនពី ១ ដល់ ១០ ឬលើសពីនេះ<br>- ប្រាប់បានពីរបៀបគូសតាមស្នាមចុចលេខពី ១ ដល់ ៥ ឬ | ៤០ ម៉ |

| | | | |
|---|---|---|---|
| | | លើសពីនេះ<br>**បំណិនសម្បទា**<br>- រាប់ចំនួន លេខ និងយល់ន័យពី ១ ដល់ ១០ ឬលើសពីនេះ<br>- បន្ថែម និងដកចំនួនពី ១ ដល់ ៥ ឬលើសពីនេះ ដោយប្រើវត្ថុ រូបី និងរាប់ចំនួនសរុប<br>- ប្រៀបធៀបចំនួនស្មើគ្នា តិចជាង ឬច្រើនជាងក្នុងចំនួន ១ ដល់ ៥ ឬលើសពីនេះ<br>- គូសតាមស្នាមចុចលេខពី ១ ដល់ ៥ ឬលើសពីនេះ។<br>**ចរិយាសម្បទា**<br>- រហ័សរហួនក្នុងការរាប់ចំនួន និងការគិតលេខ។ | |
| | **ការគិត និងវិភាគគ្រប់ជ្រុងជ្រោយ** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីចំនួនវត្ថុឬរូបភាព ចំនួនចំណុច និងលេខដែលត្រូវផ្គុំ<br>**បំណិនសម្បទា**<br>- ផ្គុំចំនួនវត្ថុឬរូបភាពទៅនឹងចំនួនចំណុច ចំនួនវត្ថុឬរូបភាពទៅនឹងលេខ ចំនួនចំណុចទៅនឹងលេខ។<br>**ចរិយាសម្បទា**<br>- មានភាពក្លាហាន ជឿជាក់ និងសម្រេចចិត្តបាន ត្រឹមត្រូវ ។ | **១៥ ម៉** |
| **រង្វាស់រង្វាល់** | **បញ្ញត្តិស្ដីពីរង្វាស់រង្វាល់** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីបញ្ញត្តិ ខ្ពស់និងទាប វែងនិងខ្លី ។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបខ្ពស់និងទាប វែងនិងខ្លី។<br>**ចរិយាសម្បទា**<br>- សហការអំណត់ ឧស្សាហ៍ព្យាយាម និងប្រុងប្រយ័ត្នក្នុងការវាស់ និងប្រៀបធៀប។ | **៥ ម៉** |
| **រូបរាង និងលំហ** | **បញ្ញត្តិនៃរូបរាង និងលំហ** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះរាងធរណីមាត្រសាមញ្ញ ដែលមានរាងរង្វង់ ចតុកោណកែង និងរាងផ្សេងៗទៀត<br>- ប្រាប់បានពីទីតាំងវត្ថុធៀបទៅនឹងវត្ថុមួយទៀតដោយប្រើ ពាក្យដូចជា ខាងលើ ខាងក្រោម ខាងឆ្វេង ខាងស្ដាំជាដើម។ | **១៥ ម៉** |

| | | | |
|---|---|---|---|
| | | **បំណិនសម្បទា**<br>- បង្ហាញបានពីរាងធរណីមាត្រ រង្វង់ ចតុកោណកែង និងរាង ផ្សេងៗទៀត<br>- បង្ហាញពីទីតាំងរបស់វត្ថុធៀបទៅនឹងវត្ថុមួយទៀតដោយប្រើពាក្យដូចជា ខាងលើ  ខាងក្រោម ខាងឆ្វេង ខាងស្តាំជាដើម។<br>**ចរិយាសម្បទា**<br>- សហការគ្នាក្នុងការអនុវត្តសកម្មភាពឱ្យបានល្អ។ | |
| **ទំហំ និងពណ៌** | ចំណាត់ក្រុម និង លំដាប់លំដោយ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបរៀបវត្ថុតាមលំដាប់  តាមក្រុមប្រភេទ  ទំហំ និងពណ៌។<br>**បំណិនសម្បទា**<br>- រៀបវត្ថុតាមលំដាប់ តាមក្រុមប្រភេទ ទំហំ និងពណ៌។<br>**ចរិយាសម្បទា**<br>- ទម្លាប់ប្រើប្រាស់ និងទុកដាក់សម្ភារៈនានា ទៅតាមប្រភេទ ឬក្រុមឱ្យមានសណ្តាប់ធ្នាប់ ។ | ១៥ ម៉ |
| **បំណិនពិចារណាក្នុងសង្គម** | ភាពខុសគ្នារវាងព្រឹត្តិការណ៍ដែលកើតឡើងក្នុងអតីតកាល បច្ចុប្បន្ន និងអនាគត (ផ្តោតលើពេលវេលា) | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះថ្ងៃក្នុងសប្តាហ៍តាមលំដាប់លំដោយពីថ្ងៃអាទិត្យរហូតដល់ថ្ងៃសៅរ៍<br>- ប្រាប់ពីព្រឹត្តិការណ៍ដែលកន្លងហួស កំពុងកើតឡើង និងមិនទាន់មកដល់ ។<br>**បំណិនសម្បទា**<br>- រាប់ឈ្មោះថ្ងៃនៅក្នុងសប្តាហ៍តាមលំដាប់លំដោយពី ថ្ងៃអាទិត្យរហូតដល់ថ្ងៃសៅរ៍<br>- រៀបរាប់លំដាប់សកម្មភាពដែលកន្លងហួស កំពុងកើតឡើង និងមិនទាន់មកដល់។<br>**ចរិយាសម្បទា**<br>- មានទម្លាប់សង្កេត ចំណាំពេលវេលា និងហេតុការណ៍ដែលបានកើតឡើង ។ | ៩ ម៉ |
| | ចំណេះដឹងនៃការប្រើប្រាស់រូបិយប័ណ្ណជាតិមួយចំនួន | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះ និងប្រភេទប្រាក់រៀលរបស់ខ្មែរដូចជាក្រដាស | ៦ ម៉ |

| | | | |
|---|---|---|---|
| | | ៥០៛ ១០០៛ ៥០០៛ និងលើសពីនេះ។<br>**បំណិនសម្បទា**<br>- ប្រើប្រាក់រៀលតាមតម្លៃសម្រាប់ទិញនំ និងវត្ថុផ្សេងៗ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ និងឱ្យតម្លៃប្រាក់រៀលរបស់ជាតិខ្មែរ ។ | |

## មុខវិជ្ជា ៖ ភាសាខ្មែរ (១៤០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **ការស្ដាប់** | ស្ដាប់គេនិយាយ និងមានសមត្ថភាពស្ដាប់ដោយធ្វើតាមការណែនាំងាយៗ | **វិជ្ជាសម្បទា**<br>- ប្រាប់ខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ<br>- ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់ ដោយអនុវត្តតាមការណែនាំ ។<br>**បំណិនសម្បទា**<br>- ធ្វើសកម្មភាពតាមការណែនាំ ២ដំណាក់ ឬលើសពីនេះ ដូចជា៖ រើសអាវរួចយកមកជូនម៉ាក់ជាដើម<br>- រៀបរូបភាព និងនិយាយតាមដំណើររឿងដែលបានបង្ហាញ<br>- ឆ្លើយតបនឹងសំណួរសាមញ្ញៗ យ៉ាងតិច ២សំណួរ។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ស្ដាប់ការនិទានរឿងដោយសប្បាយរីករាយមិនរំខានមិត្តភក្ដិ<br>- គោរពតាមការណែនាំដោយការពេញចិត្ត។ | ១២ ម៉ |
| **ការសន្ទនា** | សន្ទនាដោយប្រើពាក្យ ឬឃ្លាសមស្របតាមវ័យ(ភាសាបង្ហាញអារម្មណ៍ និងមនោសញ្ចេតនា) | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីសកម្មភាពការងារនានា ដែលខ្លួនធ្វើកន្លងមកទៅកាន់មិត្តភក្ដិ ឬមនុស្សធំ។<br>**បំណិនសម្បទា**<br>- សន្ទនាពីសកម្មភាពការងារនានា ដែលខ្លួនបានធ្វើកន្លងមកទៅមិត្តភក្ដិ ឬមនុស្សធំ ដោយប្រើពាក្យ ឬឃ្លាបានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយក្នុងការសន្ទនាតាមការណែនាំ<br>- បង្ហាញឥរិយាបថសមរម្យ រង់ចាំវេនដើម្បីនិយាយ និងចូលរួមក្នុងការសន្ទនា។ | ៨ ម៉ |

| | | | |
|---|---|---|---|
| **ការប្រើពាក្យតាមវេយ្យាករណ៍** | ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីពាក្យដែលទាក់ទងនឹងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ និងសកម្មភាពចាំបាច់មួយចំនួន<br>- ប្រាប់បានពីពាក្យដែលទាក់ទងនឹងសត្វ វត្ថុដែលធ្លាប់ស្គាល់។<br>**បំណិនសម្បទា**<br>- រៀបរាប់សត្វ និងវត្ថុនានាដែលគេធ្លាប់ស្គាល់ចំនួន៣ ឬលើសពីនេះ<br>- និយាយជាល្បះខ្លីៗ ឱ្យបានច្រើន និងត្រឹមត្រូវ ដូចជាខ្ញុំទៅបន្ទប់ទឹកជាដើម។<br>**ចរិយាសម្បទា**<br>- ទម្លាប់និយាយពាក្យ និងឃ្លាដោយមានភាពជឿជាក់។ | ១៦ ម៉ |
| **ប្រើពាក្យសម្ដីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង** | ទំនាក់ទំនងដោយប្រើពាក្យសម្ដី | **វិជ្ជាសម្បទា**<br>- ប្រាប់ចំណងជើងរឿង និងអត្ថន័យរឿងតាមរូបភាព<br>- ប្រាប់បានពីសកម្មភាពដែលគេពេញចិត្តក្រោយពីស្ដាប់រឿងនិទានរួច។<br>**បំណិនសម្បទា**<br>- និទានរឿងតាមរូបភាពឱ្យអ្នកដទៃស្ដាប់<br>- និយាយពីសកម្មភាពដែលគេពេញចិត្តក្រោយពីស្ដាប់រឿងនិទានរួច។<br>**ចរិយាសម្បទា**<br>- ទម្លាប់ប្រើពាក្យសម្ដីដោយការគោរពទៅវិញទៅមក។ | ១២ ម៉ |
| | ទំនាក់ទំនងដោយប្រើកាយវិការ និងនិមិត្តសញ្ញា | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីនិមិត្តសញ្ញាសាធារណៈទៅកាន់អ្នកដទៃចំនួន២ ដូចជា បន្ទប់ទឹកស្រី បន្ទប់ទឹកប្រុសជាដើម។<br>**បំណិនសម្បទា**<br>- បង្ហាញនិមិត្តសញ្ញាសាធារណៈដើម្បីទំនាក់ទំនងជាមួយអ្នកដទៃចំនួន ២ ។<br>**ចរិយាសម្បទា**<br>- ឈ្លាសវៃក្នុងការទំនាក់ទំនងជាមួយ ដៃគូរបស់ខ្លួននៅពេល | ៤ ម៉ |

| | | | |
|---|---|---|---|
| | | សម្តែងកាយវិការ និងបង្ហាញនិមិត្តសញ្ញា។ | |
| | **និមិត្តសញ្ញាតំណាងឱ្យសត្វ ឬវត្ថុនានា** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឈ្មោះសត្វ វត្ថុ ឱ្យបានចំនួន ២ តាមរយៈការធ្វើចលនាត្រាប់តាមនិមិត្តសញ្ញា។<br>**បំណិនសម្បទា**<br>- បង្ហាញនិមិត្តសញ្ញា ១ ឱ្យកុមារធ្វើចលនាត្រាប់តាម និងប្រាប់ឈ្មោះសត្វ ឬវត្ថុបានចំនួន ២។<br>**ចរិយាសម្បទា**<br>- សម្តែងនូវអារម្មណ៍សប្បាយរីករាយក្នុងការបង្ហាញ និងប្រាប់ឈ្មោះសត្វ វត្ថុដែលបានរកឃើញ។ | ៨ ម៉ |
| **ការស្គាល់តួអក្សរ** | **ការប្រើញាណរបស់ខ្លួន ដើម្បីអភិវឌ្ឍបំណិនសមត្ថភាពទាំង ៦** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះសត្វ  វត្ថុផ្សេងៗ ដោយស្តាប់សំឡេង ឬសង្កេតកាយវិការ<br>- ប្រាប់បានពីរបៀបលេងល្បែងបុរេសំណេរ។<br>**បំណិនសម្បទា**<br>- បង្ហាញឈ្មោះសត្វ ឬវត្ថុផ្សេងៗតាមរយៈការស្តាប់សំឡេង និងការសង្កេតកាយវិការ<br>- លេងល្បែងបុរេសំណេរដោយប្រើបំណិនសមត្ថភាពទាំង៦។<br>**ចរិយាសម្បទា**<br>- មានចំណូលចិត្ត និងសប្បាយរីករាយក្នុងការលេងល្បែង និងមានការចងចាំល្អ។ | ២០ ម៉ |
| | **ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង និងកំណាព្យ** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីទិសនៃសូរសំឡេងសត្វ ឬវត្ថុនានានៅក្នុងបរិស្ថាន<br>- ប្រាប់ពីចំណងជើង និងអត្ថន័យនៃកំណាព្យ។<br>**បំណិនសម្បទា**<br>- បង្ហាញភាពខុសគ្នាខ្លះៗនៃសូរសំឡេងសត្វ វត្ថុនានាក្នុងបរិស្ថាន<br>- សូត្រកំណាព្យត្រូវតាមវាក្យស័ព្ទ និងលំនាំបទ។<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយ័ត្នក្នុងការស្តាប់សូរសំឡេង និងចូលចិត្ត សូត្រកំណាព្យ។ | ១៦ ម៉ |

| | | | |
|---|---|---|---|
| | **ការយល់ដឹងអំពីបញ្ញត្តិនៃសំណេរ** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបរៀបវត្ថុតូចៗលើរូបភាពងាយៗដោយគោរពតាមទិសនៃសំណេរ។<br>**បំណិនសម្បទា**<br>- រៀបវត្ថុតូចៗលើរូបភាពងាយៗដោយគោរពតាមទិសនៃសំណេរ។<br>**ចរិយាសម្បទា**<br>- អំណត់ព្យាយាម សហការគ្នា និងរង់ចាំវេនក្នុងការតម្រៀបវត្ថុតូចៗ។ | **១២ ម៉** |
| | **ការយល់ដឹង និងពេញចិត្តអំពីការអាន និងការប្រើប្រាស់ឯកសារសំណេរ ឬឯកសារផ្សេងៗ** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបបើកសៀវភៅរឿងនិទានពីឆ្វេងទៅស្តាំមិនរំលងទំព័រ និងអានតាមរូបភាព<br>- ប្រាប់ពីអត្ថន័យរបស់រូបភាពក្នុងសៀវភៅរឿងនិទាន។<br>**បំណិនសម្បទា**<br>- អានរូបភាព ឬនិយាយរឿងតាមរូបភាពដោយបើកទំព័រសៀវភៅត្រឹមត្រូវតាមលំដាប់លំដោយពីឆ្វេងទៅស្តាំមិនរំលងទំព័រ<br>- រៀបរាប់ពីអត្ថន័យរបស់រូបភាពក្នុងសៀវភៅរឿងនិទាន។<br>**ចរិយាសម្បទា**<br>- ទម្លាប់ល្អក្នុងការប្រើប្រាស់ និងថែរក្សាសៀវភៅ។ | **១២ ម៉** |
| **សមត្ថភាពគូស និងសរសេរអក្សរ** | **បំណិនសរសេរកាន់តែប្រសើរឡើង** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបគូសបំពេញ និងគូសតាមស្នាមចុច រូបគំនូរដែលងាយៗ។<br>**បំណិនសម្បទា**<br>- គូសបំពេញ និងគូសតាមស្នាមចុចរូបគំនូរដែលងាយៗ។<br>**ចរិយាសម្បទា**<br>- ចូលចិត្ត ព្យាយាម អំណត់ និងមានបម្រុងប្រយ័ត្នក្នុងការកាន់ខ្មៅដៃគូសភ្ជាប់រូបគំនូរងាយៗ។ | **២០ ម៉** |

## ៧.២- កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាកម្រិតមធ្យម (កុមារអាយុ៤ឆ្នាំ)

### មុខវិជ្ជា ៖ ចិត្តចលភាព (២១០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **បំណិនចលករតូច** | ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។<br>**បំណិនសម្បទា**<br>- កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ។<br>**ចរិយាសម្បទា**<br>- មានអំណត់ តស៊ូព្យាយាម និងសប្បាយរីករាយក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ និងជោគជ័យ។ | ៣៥ ម៉ |
| **បំណិនចលករធំ** | ការហ្វឹកហាត់បង្កើនកម្លាំង និងការសម្របសម្រួលរវាងចលនាសាច់ដុំតូច និងសាច់ដុំធំ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបដើរ រត់ វារ លូន លោត បោះចុះ និងឡើងទៅតាមគោលដៅ។<br>**បំណិនសម្បទា**<br>- ដើរទប់ខ្លួនឱ្យមានលំនឹងលើគំនូសខ្សែ ដោយដៃកាន់វត្ថុនានា<br>- រត់នៅមួយកន្លែង រត់យឺត រត់លឿន<br>- វារលូន លើកន្ទេល កម្រាលឥដ្ឋ សំបកកង់<br>- លោតជើងម្ខាងទៅមុខចម្ងាយ ២ម៉ែត ឬលើសពីនេះរួចលោតត្រឡប់ក្រោយវិញដោយមិនទម្លាក់ជើង<br>- ឡើង និងចុះជណ្តើរខ្សែពួរកម្ពស់១ម៉ែត្រ ឬលើសពីនេះ<br>- បោះបាល់ចំនួន៣ដង ដោយដៃទាំងពីរចូលក្នុងផ្ទាំងក្រដាសរាងការេទំហំ៣០សម x៣០សម ចម្ងាយ២ម៉ែត្រ ឬលើសពីនេះ។<br>**ចរិយាសម្បទា**<br>- បង្ហាញនូវអារម្មណ៍សប្បាយរីករាយ និងចូលចិត្តក្នុងការធ្វើចលនា ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ។ | ៣៥ ម៉ |
| **ភាពរឹងមាំនៃរាងកាយ និងចលនា** | ការបង្កើនកម្លាំងនិងការប្រឈមទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព | **វិជ្ជាសម្បទា**<br>- បង្ហាញពីរបៀបដើរ រត់ លោតទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។<br>**បំណិនសម្បទា**<br>- អនុវត្តសកម្មភាពមួយបានទន់ភ្លន់ រហ័សរហួន និងរឹងមាំដោយផ្តើមចេញពីចលនាមូលដ្ឋានងាយៗទៅលំបាក ចំនួន ២ឡើងទៅក្នុងនោះមានការដើរ រត់ លោត ឬលើសពីនេះតាមរយៈចលនាចរន្តហាត់ប្រាណតាមរឿងនិទាន តាមបទចម្រៀង តាមបទភ្លេង និងល្បែងចលនា។<br>**ចរិយាសម្បទា**<br>- ក្លាហាន ជឿជាក់លើសមត្ថភាព និងកម្លាំងរបស់ខ្លួន ថាមានសុវត្ថិភាព ក្នុងពេលធ្វើសកម្មភាពឆ្លងកាត់ឧបសគ្គ ។ | ១៤០ ម៉ |

**មុខវិជ្ជា ៖ វិទ្យាសាស្ត្រ (១០៥ ម៉ោង)**

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **អាហារូបត្ថម្ភ** | ចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះបន្លែ ផ្លែឈើ និងសាច់ឱ្យបាន៥មុខ ឬលើសពីនេះ<br>- ប្រាប់ពីអាហារដែលមានគុណភាព គ្មានគុណភាពនិងសារៈសំខាន់នៃការញ៉ាំអាហារបន្លែ ផ្លែឈើ និងសាច់។<br>**បំណិនសម្បទា**<br>- ធ្វើចំណាត់ថ្នាក់អាហារទៅតាមក្រុមផ្លែឈើ ក្រុមសាច់ និងបន្លែ<br>- បង្ហាញពីអាហារដែលមានគុណភាព គ្មានគុណភាព និសារៈសំខាន់នៃការញ៉ាំអាហារ បន្លែ ផ្លែឈើ និងសាច់។<br>**ចរិយាសម្បទា**<br>- មានចំណូលចិត្តញ៉ាំអាហារ ផ្លែឈើ និងបន្លែដែលមាន ប្រយោជន៍ចំពោះសុខភាព<br>- មានទម្លាប់ដាំ និងថែរក្សាដំណាំ បន្លែ និងផ្លែឈើ។ | ១៨ ម៉ |
| **បំណិនអនាម័យ** | ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីទម្លាប់ល្អទាំងឡាយមុន និងក្រោយពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាត និងអនាម័យខ្លួនប្រាណ<br>- ប្រាប់បានពីរបៀបរៀបចំទីកន្លែងគេង និងសម្ភារៈផ្ទាល់ខ្លួនឱ្យបានស្អាត<br>- ប្រាប់ពីការប្រុងប្រយ័ត្នពេលក្អក កណ្ដាស់ និងសម្អាតច្រមុះ<br>- ប្រាប់បានពីទីកន្លែងទុកដាក់សំរាមតាមការកំណត់ ។<br>**បំណិនសម្បទា**<br>- លាងសម្អាតដៃតាមពេលវេលាដូចជា មុន និងក្រោយពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាត និងក្រោយពេលចេញពីបង្គន់<br>- ខ្ទប់មាត់នៅពេលក្អក កណ្ដាស់ និងសម្អាតច្រមុះពេលហៀរសំបោរ<br>- ចោលសំរាមតាមកន្លែងកំណត់<br>- សម្អាតខ្លួនប្រាណដូចជា ងូតទឹក សិតសក់ ដុសធ្មេញ សម្អាតដៃជើង និងស្លៀកពាក់ដោយខ្លួនឯង<br>- រៀបចំកន្លែងគេង និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនឱ្យបានស្អាត។ | ៩ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- មានទម្លាប់អនាម័យក្នុងការរស់នៅដូចជា មុន និងក្រោយ ពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាត ចូលបង្គន់អនាម័យ និង សម្អាតខ្លួនប្រាណ ជាដើម<br>- ទម្លាប់រៀបចំកន្លែងគេង និងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនឱ្យបានស្អាត និងមានសណ្តាប់ធ្នាប់ | |
| **ប្រតិបត្តិដោយសុវត្ថិភាព** | **ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះឪពុកម្តាយឬអ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់ និងអាសយដ្ឋានរបស់ខ្លួនដើម្បីឱ្យគេជួយនៅពេលមានបញ្ហា<br>- ប្រាប់ពីគ្រោះថ្នាក់ដែលបណ្តាលមកពីការលេងភ្លើង អគ្គិសនី ពាងទឹក ថ្នាំសម្លាប់សត្វល្អិត ស្លាកសញ្ញាមីន វត្ថុមុតស្រួច និងស្រះទឹក។<br>**បំណិនសម្បទា**<br>- បង្ហាញពីឈ្មោះឪពុកម្តាយ អ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់ និងអាសយដ្ឋានរបស់ខ្លួននៅពេលវង្វេងផ្លូវ?<br>- រៀបរាប់ពីគ្រោះថ្នាក់ដែលបណ្តាលមកពីការលេងភ្លើង អគ្គិសនី ស្រះទឹក ពាងទឹក ថ្នាំសម្លាប់សត្វល្អិត ស្លាកសញ្ញាមីន និងវត្ថុមុតស្រួច ។<br>**ចរិយាសម្បទា**<br>- ក្លាហាន មិនតក់ស្លុតក្នុងការប្រាប់ឈ្មោះឪពុកម្តាយ អ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់នៅពេលវង្វេងផ្លូវ<br>- ចៀសវាងសកម្មភាពមួយចំនួនដែលនាំឱ្យមានគ្រោះថ្នាក់ ដូចជាលេងភ្លើង អគ្គិសនី ថ្នាំសម្លាប់សត្វល្អិត ស្លាកសញ្ញាមីន វត្ថុមុតស្រួច និងស្រះទឹក ។ | ១២ ម៉ |
| **ការរស់នៅប្រចាំថ្ងៃ** | **ការស្វែងយល់ដោយការសង្កេត** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះ លក្ខណៈរូបធាតុ និងចរិតលក្ខណៈរបស់សត្វ<br>- ប្រាប់បានពីវត្ថុមួយធ្ងន់ ឬស្រាល លិច និងអណ្តែត។<br>**បំណិនសម្បទា**<br>- រៀបរាប់ឈ្មោះសត្វ ចរិតលក្ខណៈ លក្ខខណ្ឌ រស់នៅ វដ្តនៃសត្វ ការប្រៀបធៀបសត្វ និងផលប្រយោជន៍<br>- បញ្ជាក់បានពីទម្ងន់វត្ថុមួយដែលដាក់លើបាតដៃដឹងថា ធ្ងន់ ឬស្រាល និងវត្ថុដាក់ក្នុងទឹកដឹងថាលិច ឬអណ្តែត។ | ១២ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលចិត្តចិញ្ចឹម និងថែរក្សាសត្វ<br>- ប្រុងប្រយ័ត្នក្នុងការចាប់កាន់វត្ថុ ចៀសវាងគ្រោះថ្នាក់។ | |
| | លក្ខណៈមេឃ និងអាកាសធាតុ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីទិសពេលវេលាដែលព្រះអាទិត្យរះ និងលិច<br>- ប្រាប់ពីអាកាសធាតុ ព្រឹត្តិការណ៍មុន កំពុង និងក្រោយ ភ្លៀងធ្លាក់។<br>**បំណិនសម្បទា**<br>- បង្ហាញពីទិស  ពេលវេលាដែលព្រះអាទិត្យរះ និងលិច<br>- រៀបរាប់ពីអាកាសធាតុ និងព្រឹត្តិការណ៍មុន កំពុង និងក្រោយ ពេលភ្លៀងធ្លាក់។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្នក្នុងការដើរហាលក្តៅ ហាលភ្លៀង(ពាក់មួក ឬទទូរ)។ | ៦ ម៉ |
| | លក្ខណៈរូបធាតុ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវត្ថុដែលធ្វើពីឈើ ដែក ជ័រប្លាស្ទិច និងថ្មបានយ៉ាងតិច ៤<br>- ប្រាប់ពីភាពខុសគ្នាវត្ថុធាតុដើមនៃសម្ភារៈដោយប្រើបញ្ញត្តិដូចជាៈ រឹង  ទន់  ក្តៅ  ត្រជាក់  គ្រើម  រលោង ជាដើម ។<br>**បំណិនសម្បទា**<br>- ញែកបានរវាងវត្ថុធ្វើពីឈើ ដែក ជ័រប្លាស្ទិច និងថ្ម<br>- ញែកបានពីភាពខុសគ្នារវាងវត្ថុធាតុដើមនៃសម្ភារៈដោយប្រើបញ្ញត្តិ រឹង ទន់ ក្តៅ ត្រជាក់ គ្រើម រលោង...។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វត្ថុដែលបង្កគ្រោះថ្នាក់។ | ៩ ម៉ |
| | អំពីរាងកាយផ្ទាល់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះផ្នែកផ្សេងៗនៃរាងកាយរបស់មនុស្សឱ្យបាន ៦ផ្នែក។<br>**បំណិនសម្បទា**<br>- បង្ហាញពីផ្នែកផ្សេងៗ និងមុខងាររបស់រាងកាយមនុស្សដូចជា ភ្នែកសម្រាប់មើល ត្រចៀកសម្រាប់ស្តាប់ មាត់សម្រាប់ហូបបាយ ច្រមុះហិតក្លិន...។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្ន និងថែរក្សាផ្នែកផ្សេងៗនៃរាងកាយ។ | ៦ ម៉ |

| | | | |
|---|---|---|---|
| | ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗ ដែលប្រើប្រាស់ក្នុងផ្ទះប្រចាំថ្ងៃយ៉ាងតិចចំនួន ៣<br>- ប្រាប់ឈ្មោះសំណង់សាមញ្ញៗ មួយចំនួន។<br>**បំណិនសម្បទា**<br>- បង្ហាញឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗដែលប្រើក្នុងជីវភាពប្រចាំថ្ងៃយ៉ាងតិចចំនួន ៣ ដូចជា៖ ទូរទស្សន៍ កង្ហារ ទូរស័ព្ទ<br>- សាងសង់សំណង់សាមញ្ញៗដោយប្រើដីឥដ្ឋ ឬដុំឥដ្ឋ ឬដុំឈើ។<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយ័ត្នក្នុងការប៉ះពាល់ ធ្វើសកម្មភាពប្រកបដោយសុវត្ថិភាព ។ | ៦ ម៉ |
| | មធ្យោបាយធ្វើដំណើរ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីមធ្យោបាយធ្វើដំណើរផ្លូវគោកចំនួន២ ផ្លូវទឹកចំនួន២ ផ្លូវដែកចំនួន១ និងផ្លូវអាកាសចំនួន១។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីឈ្មោះ ទ្រង់ទ្រាយ និងផលប្រយោជន៍របស់មធ្យោបាយធ្វើដំណើរបានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលរួមថែរក្សាផលប្រយោជន៍របស់មធ្យោបាយធ្វើដំណើរនីមួយៗ។ | ៦ ម៉ |
| **បំណិនពិចារណា** | ការយល់ដឹងពីហេតុ និងផល | **វិជ្ជាសម្បទា**<br>- ប្រាប់ពីលក្ខណៈរបស់អាកាសធាតុ ស្ថានភាពវត្ថុអ្វីមួយ<br>- ប្រាប់បានពីសកម្មភាពដែលជះឥទ្ធិពលលើវត្ថុនានា ដូចជា បាល់មានរាងមូលងាយនឹងរមៀល ដុំឈើមានជ្រុង មិនរមៀល។<br>**បំណិនសម្បទា**<br>- ប៉ាន់ស្មានទុកអំពីបាតុភូតនានា ដូចជាអាចនឹងមានភ្លៀងនៅពេលឃើញមេឃងងឹត ឬឮផ្គរលាន់<br>- បញ្ជាក់បានពីសកម្មភាពដែលជះឥទ្ធិពលលើវត្ថុនានាដូចជា បាល់មានរាងមូលងាយរមៀល ដុំឈើមានជ្រុងមិនរមៀលជាដើម។ | ៩ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- ឈ្លាសវៃក្នុងការគិតពិចារណាតាមអ្វីដែលមើលឃើញ។ | |
| **បំណិនក្នុងសង្គម** | **ចំណេះដឹងអំពីសហគមន៍** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះមុខរបរផ្សេងៗដែលមាននៅក្នុងមូលដ្ឋានផ្ទាល់ ។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីមុខរបរផ្សេងៗ ដែលមាននៅក្នុងមូលដ្ឋានផ្ទាល់<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលរួមសហការជាមួយការប្រកបតាមមុខរបរផ្សេងៗ | ១២ ម៉ |

## មុខវិជ្ជា ៖ សិក្សាសង្គម (៤៩០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **ការយល់ដឹងពីតម្លៃមនុស្ស** | **ការយល់ដឹងពីតម្លៃ និងចរិតលក្ខណៈរបស់មនុស្ស** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអំពើមិនល្អ និងអំពើល្អ( បុណ្យ បាប )<br>- ប្រាប់ពីរបៀបគួរសម (ខ្ញុំ បាទ ចាស អរគុណ សុំទោស ជម្រាបសួរ ជម្រាបលា និងដើរឱនៗ ដោះមួក ឬក្រមា)។<br>**បំណិនសម្បទា**<br>- ប្រើពាក្យគួរសមទៅកាន់មនុស្សគ្រប់រូប (ខ្ញុំ បាទ ចាស អរគុណ សូមទោស ជម្រាបសួរ ជម្រាបលា ដើរឱនៗ ដោះមួក ឬក្រមា)<br>- កំណត់បានពីអំពើមិនល្អ អំពើល្អ បុណ្យ និងបាប ។<br>**ចរិយាសម្បទា**<br>- សម្តែងអាកប្បកិរិយាគោរពអ្នកដទៃបានត្រឹមត្រូវ។ | ៥ ម៉ |
| **ការលើកតម្កើងវប្បធម៌** | **ការលើកតម្កើងវប្បធម៌របស់ខ្លួន** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះបុណ្យប្រពៃណីជាតិខ្មែរដូចជាបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ ជាដើម<br>- ប្រាប់ពីទង់ជាតិរបស់ប្រទេសកម្ពុជា និងទង់សាសនា<br>- ប្រាប់បានពីឈ្មោះឧបករណ៍ភ្លេងខ្មែរដូចជាស្គរ ខ្លុយ ទ្រ រនាតជាដើម<br>- ប្រាប់បានពីទីកន្លែងសំខាន់ៗដូចជា វត្តអារាម អង្គរវត្តជាដើម<br>- ប្រាប់បានពីសម្លៀកបំពាក់ប្រពៃណីជនជាតិខ្មែរដូចជា ហូល ក្រមា ផាមួង អាវប៉ាក់ ជាដើម។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីការប្រារព្ធពិធីបុណ្យប្រពៃណីជាតិខ្មែរដូចជា បុណ្យចូលឆ្នាំ | ១៥ ម៉ |

| | | | |
|---|---|---|---|
| | | ខ្មែរ បុណ្យភ្ជុំបិណ្ឌ ជាដើម<br>- បង្ហាញពីឧបករណ៍ភ្លេងខ្មែរដូចជា ស្គរ ខ្លុយ ទ្រ រនាត ជាដើម<br>- បង្ហាញពីសម្លៀកបំពាក់ប្រពៃណីជនជាតិខ្មែរ ដូចជា ក្រមា ហូល ផាមួង អាវប៉ាក់<br>- ច្រៀងបទគោរពទង់ជាតិបាន ២វគ្គ (បទនគររាជ)<br>- បង្ហាញពីទីកន្លែងសំខាន់ៗដូចជា វត្តអារាម អង្គរវត្ត ជាដើម<br>- កំណត់បានពីទង់ជាតិប្រទេសកម្ពុជា និងទង់សាសនា។<br>**ចរិយាសម្បទា**<br>- ទម្លាប់សំពះនៅពេលឃើញ ចាស់ព្រឹទ្ធាចារ្យ ព្រះបដិមា ព្រះសង្ឃ និងក្នុងពេលសូត្រធម៌<br>- សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន<br>- យកចិត្តទុកដាក់គោរពទង់ជាតិបានទៀងទាត់។ | |
| **បំណិន ទំនាក់ទំនង** | អត្តសញ្ញាណរបស់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីនាមត្រកូល នាមខ្លួន និងឈ្មោះសមាជិកគ្រួសារ។<br>**បំណិនសម្បទា**<br>- ណែនាំនាមត្រកូល និងនាមខ្លួន<br>- រៀបរាប់ពីឈ្មោះសមាជិកក្នុងគ្រួសារ។<br>**ចរិយាសម្បទា**<br>- ជឿជាក់ក្នុងការណែនាំខ្លួន និងសមាជិកគ្រួសារដល់អ្នកដទៃ។ | **៥ ម៉** |
| | បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីទីកន្លែងរស់នៅ និងឈ្មោះមនុស្សជុំវិញដែលត្រូវឱ្យជួយនៅពេលមានបញ្ហា<br>- ប្រាប់ពីការងារងាយៗមួយចំនួនដូចជា ការឱ្យចំណីសត្វ ស្រោចដំណាំ បោសសម្អាតជាដើម ។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីកន្លែងរស់នៅ ឈ្មោះមនុស្សជុំវិញដែលត្រូវឱ្យជួយនៅពេលដែលខ្លួនមានបញ្ហា<br>- ជួយការងារមនុស្សធំ ដូចជាការឱ្យចំណីសត្វ ស្រោចដំណាំ សម្អាតផ្ទះ ជាដើម។ | **៥ ម៉** |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- ក្លាហានក្នុងការទាក់ទងជាមួយមនុស្សធំនៅពេលមានបញ្ហា<br>- មានទម្លាប់ជួយការងារស្រាលៗទៅតាមកម្លាំង ។ | |
| | **បំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងល្អជាមួយមិត្តភក្តិដែលមានវ័យប្រហាក់ប្រហែលគ្នា** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវត្តមាន អវត្តមានមិត្តភក្តិ កាលបរិច្ឆេទ និងទម្លាប់ល្អ<br>- ប្រាប់ពីរបៀបលេងល្បែងសេរីដែលបានលេងជាបុគ្គល ឬក្រុម<br>- ប្រាប់បានពីឈ្មោះកុមារដទៃទៀតដែលខ្លួនបានលេងជាមួយដោយមិនឈ្លោះប្រកែកគ្នា។<br>**បំណិនសម្បទា**<br>- បង្ហាញពីវត្តមាន និងអវត្តមានមិត្តភក្តិប្រចាំថ្ងៃ និងឈ្មោះថ្ងៃ ខែ ឆ្នាំប្រចាំថ្ងៃដោយប្រើប្រាស់តារាងសកម្មភាពប្រចាំថ្ងៃ និងអនុវត្តទម្លាប់ល្អជាប្រចាំ<br>- លេងល្បែងសេរីដែលខ្លួនចូលចិត្តជាបុគ្គល ឬជាក្រុម<br>- ចូលរួមលេងជាមួយកុមារដទៃទៀតដោយមិនឈ្លោះប្រកែកគ្នា<br>- បង្ហាញឈ្មោះកុមារដទៃទៀតដែលខ្លួនបានលេងជាមួយ។<br>**ចរិយាសម្បទា**<br>- គោរពពេលវេលាទៀងទាត់ និងមានទម្លាប់ល្អ<br>- សម្តែងនូវស្មារតីចែករំលែក និងការយោគយល់ក្នុងពេលលេងល្បែងជាមួយមិត្តភក្តិ។ | **៣២០ ម៉** |
| | **ការយល់ដឹងអំពីទង្វើ និងលទ្ធផល** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអំពើមិនល្អដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។<br>**បំណិនសម្បទា**<br>- ប្រព្រឹត្តអំពើទាំងឡាយណាដែលមិនប៉ះពាល់ដល់អ្នកដទៃ។<br>**ចរិយាសម្បទា**<br>- ចៀសវាងអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ និងខ្លួនឯង។ | **៥ ម៉** |
| | **ការពេញចិត្តចំពោះ លក្ខណៈផ្សេងគ្នារបស់បុគ្គល** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីលក្ខណៈសម្បត្តិរបស់មិត្តភក្តិដែលលេង ជាមួយ<br>- ប្រាប់ពីសមត្ថភាពមនុស្សម្នាក់ដែលខ្លួនស្រឡាញ់ចូលចិត្ត ។ | **៥ ម៉** |

| | | | |
|---|---|---|---|
| | | **បំណិនសម្បទា**<br>- លេងជាមួយកុមារដទៃទៀតដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ វណ្ណៈ ឬពិការភាព<br>- វាយតម្លៃបានត្រឹមត្រូវ និងគាំទ្រដោយភាពពេញចិត្តចំពោះសមត្ថភាពរបស់មិត្តភក្តិ ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយក្នុងពេលលេងជាមួយកុមារដទៃទៀតដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ វណ្ណៈ ពិការ ។ | |
| **ការយល់ដឹងអំពីខ្លួនឯង** | **ស្គាល់ពីអារម្មណ៍មួយចំនួន** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអារម្មណ៍ ឬឥរិយាបថនៃការព្រួយបារម្មណ៍ កង្វល់ក្នុងព្រឹត្តិការណ៍មួយចំនួន។<br>**បំណិនសម្បទា**<br>- បង្ហាញកាយវិការ ឬនិយាយអំពីសេចក្តីស្រឡាញ់ និងទំនាក់ទំនងជាមួយមនុស្សដែលនៅជុំវិញ។<br>**ចរិយាសម្បទា**<br>- ទំនាក់ទំនងល្អទាំងកាយវិការ និងសម្តីប្រកបដោយសេចក្តីស្រឡាញ់ជាមួយមនុស្សដែលនៅជុំវិញ។ | **៥ ម៉** |
| | **សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយធ្វើកាយវិការ ទឹកមុខ និងពាក្យសម្តី<br>- ប្រាប់ពីរបៀបសម្របខ្លួន និងទប់អារម្មណ៍មិនឱ្យឆាប់ខឹងទៅនឹងស្ថានភាពមនុស្សជុំវិញខ្លួន ។<br>**បំណិនសម្បទា**<br>- សម្តែងបានពីអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយធ្វើកាយវិការ ទឹកមុខ និងពាក្យសម្តី<br>- សម្របខ្លួន និងទប់អារម្មណ៍មិនឱ្យឆាប់ខឹងទៅនឹងស្ថានភាពមនុស្សជុំវិញខ្លួន។<br>**ចរិយាសម្បទា**<br>- ទទួលស្គាល់ភាពជោគជ័យ និងបរាជ័យរបស់ខ្លួន<br>- កែប្រែទម្លាប់អវិជ្ជមានដើម្បីរស់នៅចុះសម្រុងក្នុងសង្គម។ | **៥ ម៉** |

| | | | |
|---|---|---|---|
| **បំណិនពិចារណា** | គោលវិធីជាវិជ្ជមាននិងជំហរដើម្បីដោះស្រាយបញ្ហា | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីវិធីដោះស្រាយបញ្ហាដែលកើតមានក្នុងពេលធ្វើការងារក្រុម។<br>**បំណិនសម្បទា**<br>- បង្ហាញពីវិធីដោះស្រាយបញ្ហាផ្សេងៗ ដូចជា៖ រកវិធីផ្សេងៗដើម្បីយកបាល់ដែលនៅឆ្ងាយពីដៃបាន<br>**ចរិយាសម្បទា**<br>- សហការគ្នាល្អក្នុងពេលធ្វើការងារជាក្រុម ឬដៃគូ ។ | ៥ ម៉ |
| **បំណិនក្នុងសង្គម** | ការយល់ដឹងពីបរិស្ថានធម្មជាតិ និងវិធីការពារ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះទីកន្លែងដែលមានបរិស្ថានល្អ និងទង្វើមិន បំផ្លាញបរិស្ថានធម្មជាតិដូចជា ការចោលសំរាម ការបន្ទោរបង់ និងបំផ្លាញរុក្ខជាតិជាដើម។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីឈ្មោះទីកន្លែងដែលមានបរិស្ថានល្អ<br>- បង្ហាញនូវទង្វើដែលមិនបំផ្លាញបរិស្ថានធម្មជាតិដូចជា ការចោលសំរាម ការបន្ទោរបង់ និងបំផ្លាញរុក្ខជាតិ ជាដើម។<br>**ចរិយាសម្បទា**<br>- ចូលចិត្តរស់នៅស្អាត និងស្រឡាញ់បរិស្ថាន<br>- មានទម្លាប់ធ្វើការងារដោយសុវត្ថិភាព និងប្រុងប្រយ័ត្ន។ | ៥ ម៉ |
| **គំនូរ និងសកម្មភាពគសាង** | ការយល់ដឹង និងការពេញចិត្ត ចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបបត់ក្រដាសជារាងងាយៗដូចជា មួក កាបូប<br>- ប្រាប់ពីរបៀបសូនរូបជារាងងាយៗផ្លែឈើដោយប្រើដៃទាំងពីរ ដូចជាផ្លែឈើជាដើម<br>- ប្រាប់បានពីរបៀបគូរ ហែករូបងាយៗតាមស្នាមចុច ផាត់ពណ៌រូបភាពផ្សេងៗ និងបង្ហាញពីសកម្មភាពផ្សេងទៀតដែលបានបង្កើតស្នាដៃ។<br>**បំណិនសម្បទា**<br>- បត់ក្រដាសជារាងងាយៗដូចជា មួក កាបូប<br>- សូនរូបជារាងងាយៗផ្លែឈើដោយប្រើដៃទាំងពីរដូចជាផ្លែឈើជាដើម<br>- គូរ ហែករូបងាយៗតាមស្នាមចុចនិងផាត់ពណ៌រូបភាពផ្សេងៗ | ៣៥ ម៉ |

| | | | |
|---|---|---|---|
| | | និងបង្ហាញសកម្មភាពផ្សេងទៀតដែលបានបង្កើតស្នាដៃ<br>- បង្ហាញពីរបៀបនៃការគូរ ផាត់ ឬការផលិតឱ្យមានសោភ័ណ។<br>**ចរិយាសម្បទា**<br>- ឈ្លាសវៃ រហ័សរហួន និងប៉ិនប្រសប់ក្នុងការចាប់កាន់ បត់ សូន គូរ ហែក និង ផាត់ពណ៌ឱ្យមានសោភ័ណ ។ | |
| | **ការយល់ដឹងអំពីការឆ្លាស់វត្ថុតាមចង្វាក់ និងការគូរគំនូរ** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបដោតអង្កាំ ឬវត្ថុផ្សេងៗដែលមានប្រហោងសម្រាប់ដោតឆ្លាស់ពណ៌តាមរូបគំរូ និងគូសគំនូសផ្សេងៗ ។<br>**បំណិនសម្បទា**<br>- ដោតអង្កាំ ឬវត្ថុផ្សេងៗដែលមានប្រហោងដោយឆ្លាស់ពណ៌គ្នាតាមគំរូបានត្រឹមត្រូវ<br>- គូសចម្លងតាមរាងចតុកោណកែង និងរង្វង់លើក្រដាស ឬដី<br>- គូររូបមនុស្សយ៉ាងតិចបាន ៣ផ្នែកខុសៗគ្នា រួមមានៈ ក្បាល ដងខ្លួន ដៃ និងជើង។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយ និងចូលចិត្តធ្វើសកម្មភាពងាយៗខ្លួនឯង ដូចជាដោតអង្កាំ គូសគំនូសផ្សេងៗជាដើម ។ | ៣៥ ម៉ |
| **ចម្រៀង និងតន្ត្រី** | **ចំណេះដឹងបច្ចេកទេសការច្នៃប្រឌិត និងបទពិសោធផ្នែកតន្ត្រី** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីចំណងជើង អត្ថន័យនៃបទចម្រៀងមួយចំនួន និងរបៀបធ្វើកាយវិការ<br>- ប្រាប់បានពីរបៀបរាំតាមចង្វាក់ប្រពៃណីខ្មែរដូចជា រាំវង់ រាំក្បាច់<br>- ប្រាប់ពីរបៀបទះដៃបន្ទរ ឬគោះសម្ភារៈនានាតាមចង្វាក់ភ្លេង។<br>**បំណិនសម្បទា**<br>- ច្រៀងចម្រៀង និងធ្វើកាយវិការតាមខ្លឹមសារបទចម្រៀងបាន ១បទ ឬលើសពីនេះ<br>- ទះដៃបន្ទរ និងគោះសម្ភារៈនានា ត្រូវតាមចង្វាក់ភ្លេង<br>- រាំតាមចង្វាក់ប្រពៃណីខ្មែរដូចជា រាំវង់ រាំក្បាច់ជាដើម។<br>**ចរិយាសម្បទា**<br>- ស្រលាញ់ ចូលចិត្តបទចម្រៀង និងរបាំប្រពៃណីខ្មែរ ។ | ៤០ ម៉ |

## មុខវិជ្ជា ៖ គណិតវិទ្យា (១០៥ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **បរិមាណ និងចំនួន** | ស្គាល់ យល់ លេខគាង រាប់ចំនួននិងការគណនាលេខសាមញ្ញៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីចំនួនលេខ និងយល់ន័យពី១ ដល់ ២០ តាមលំដាប់លំដោយ ឬលើសពីនេះ<br>- ប្រាប់ពីសំណុំចំនួនតិចជាង ច្រើនជាង និងស្មើគ្នាក្នុងចំនួនពី១ ដល់ ១០ ឬលើសពីនេះ<br>- ប្រាប់បានពីរបៀបបន្ថែម និងដកចំនួនពី ១ ដល់ ១០ ឬលើសពីនេះ<br>- ប្រាប់បានពីរបៀបគូសចម្លងតាមស្នាមចុចលេខពី ១ ដល់ ១០ ឬលើសពីនេះ។<br>**បំណិនសម្បទា**<br>- រាប់ចំនួន លេខ និងយល់ន័យពី ១ ដល់ ២០ ឬលើសពីនេះ<br>- បន្ថែម និងដកចំនួនពី ១ ដល់ ១០ឬលើសពីនេះ ដោយប្រើវត្ថុរូបី និងរាប់ចំនួនសរុបបានត្រឹមត្រូវ<br>- ប្រៀបធៀបបានចំនួនស្មើគ្នា តិចជាង ឬច្រើនជាងក្នុងចំនួន ១ ដល់ ១០ ឬលើសពីនេះ<br>- គូសចម្លងតាមស្នាមចុចលេខពី១ ដល់ ១០ ឬលើសពីនេះ ។<br>**ចរិយាសម្បទា**<br>- រីករាយ ព្យាយាម អំណត់ រហ័សរហួនក្នុងការគិតលេខ ។ | ៤០ ម៉ |
| | ការគិត និង វិភាគគ្រប់ជ្រុងជ្រោយ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីចំនួនរូបភាព ទៅនឹងចំនួនចំនុច និងលេខដែលត្រូវផ្គុំ និងផ្គូផ្គង។<br>• **បំណិនសម្បទា**<br>- ផ្គុំ និងផ្គូផ្គងចំនួនរូបភាព ទៅនឹងនឹងចំនួនចំណុច ចំនួនចំណុច ទៅនឹងចំណុច ចំនួនចំណុចទៅនឹងលេខ។<br>**ចរិយាសម្បទា**<br>- មានភាពក្លាហាន និងជឿជាក់ក្នុងការសម្រេចចិត្តត្រឹមត្រូវ។ | ១៥ ម៉ |
| **រង្វាស់រង្វាល់** | បញ្ញត្តិ ស្តីពី រង្វាស់រង្វាល់ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីបញ្ញត្តិ ខ្ពស់ និងទាប វែង និងខ្លី ធ្ងន់ និងស្រាល<br>- ប្រាប់ពីវត្ថុខ្លះៗ ដែលជារង្វាស់រង្វាល់។ | ១២ ម៉ |

| | | | |
|---|---|---|---|
| | | **បំណិនសម្បទា**<br>- ប្រៀបធៀបខ្ពស់ និងទាប វែង និងខ្លី ធ្ងន់ និងស្រាល<br>វង្វាល់វត្ថុរាវ និងរឹងដោយប្រើខ្នាតរង្វាស់។<br>**ចរិយាសម្បទា**<br>- មានភាពអំណត់ឧស្សាហ៍ និងប្រុងប្រយ័ត្នក្នុងការវាស់ ការវាល់<br>និងប្រៀបធៀប។ | |
| **រូបរាង និងលំហ** | បញ្ញត្តិនៃរូបរាង និងលំហ | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះរាងធរណីមាត្រសាមញ្ញដូចជារង្វង់ ការេ ចតុកោណ<br>កែង និងត្រីកោណជាដើម<br>- ប្រាប់បានពីទីតាំងវត្ថុ ធៀបទៅនឹងវត្ថុមួយ ដោយប្រើពាក្យ ដូចជា<br>ខាងលើ ខាងក្រោម ខាងមុខ ខាងក្រោយ ខាងក្នុង ខាងក្រៅ ខាងឆ្វេង<br>និងខាងស្តាំជាដើម។<br>**បំណិនសម្បទា**<br>- បង្ហាញពីរាងធរណីមាត្រ រង្វង់ ចតុកោណកែង និងត្រីកោណ<br>- បង្ហាញទីតាំងវត្ថុធៀបទៅនឹងវត្ថុមួយដោយប្រើពាក្យ៖ ខាងលើ  ខាង<br>ក្រោម ខាងមុខ ខាងក្រោយ ខាងក្នុង  ខាងក្រៅ  ខាងឆ្វេង ខាងស្តាំ...។<br>**ចរិយាសម្បទា**<br>- សហការគ្នាក្នុងការអនុវត្តសកម្មភាពឱ្យបានល្អ ។ | ១២ ម៉ |
| **ទំហំ និងពណ៌** | ចំណាត់ក្រុម និងលំដាប់លំដោយ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីការរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌<br>- ប្រាប់បានពីរបៀបរៀបតាមចង្វាក់ដដែលៗនូវរូបរាងធរណីមាត្រតាម<br>ពណ៌បន្តគ្នាតាមលំដាប់លំដោយ។<br>**បំណិនសម្បទា**<br>- រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌<br>- រៀបរូបរាងធរណីមាត្រ តាមរាង និងពណ៌បន្តគ្នាតាមចង្វាក់ដដែលៗ។<br>**ចរិយាសម្បទា**<br>- ទម្លាប់ប្រើប្រាស់ និងទុកដាក់ សម្ភារៈនានាទៅតាម ប្រភេទ ឬក្រុម<br>ឱ្យមានសណ្តាប់ធ្នាប់ ។ | ១២ ម៉ |
| **បំណិនពិចារណាក្នុងសង្គម** | ភាពខុសគ្នារវាងព្រឹត្តិការណ៍ដែលកើតឡើងក្នុងអតីតកាល បច្ចុប្បន្ន និង | **វិជ្ជាសម្បទា**<br>- ប្រាប់ពីពេលដែលកន្លងហួស កំពុង និងមិនទាន់ដល់<br>- ប្រាប់បានពីឈ្មោះថ្ងៃក្នុងសប្តាហ៍តាមលំដាប់លំដោយ ពីថ្ងៃអាទិត្យ<br>រហូតដល់ថ្ងៃសៅរ៍ | ៨ ម៉ |

| | | | |
|---|---|---|---|
| | អនាគត (ដោយផ្ដោតលើពេលវេលា) | - ប្រាប់បានពីរូបភាពតាមលំដាប់លំដោយពេលវេលាដូចជា ពេលព្រឹក ពេលថ្ងៃត្រង់ និងពេលយប់ ។<br>**បំណិនសម្បទា**<br>- រាប់ឈ្មោះថ្ងៃនៅក្នុងសប្ដាហ៍តាមលំដាប់៖ ថ្ងៃអាទិត្យ...សៅរ៍<br>- រៀបរាប់ឈ្មោះថ្ងៃ ម្សិលមិញ ថ្ងៃនេះ និងថ្ងៃស្អែក<br>- រៀប និងបង្ហាញពីរូបភាពទៅតាមលំដាប់លំដោយពេលវេលាដូចជា ពេលព្រឹក ពេលថ្ងៃត្រង់ និងពេលយប់។<br>**ចរិយាសម្បទា**<br>- ទម្លាប់អនុវត្តសកម្មភាពប្រចាំថ្ងៃបានទៀងទាត់ពេលវេលា ។ | |
| | ចំណេះដឹងនៃការប្រើប្រាស់រូបិយប័ណ្ណជាតិមួយចំនួន | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះ និងប្រភេទប្រាក់រៀលរបស់ខ្មែរ៖ ក្រដាស ១០០៛ ៥០០៛ និង ១ ០០០៛ ។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់ប្រាក់រៀលតាមតម្លៃសម្រាប់ទិញនំ និងវត្ថុផ្សេងៗ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ និងឱ្យតម្លៃប្រាក់រៀលរបស់ជាតិខ្មែរ ។ | ៦ ម៉ |

## មុខវិជ្ជា ៖ ភាសាខ្មែរ (១៤០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលសិក្សា | ម៉ោង |
|---|---|---|---|
| **ការស្ដាប់** | ស្ដាប់គេនិយាយ និងមានសមត្ថភាពស្ដាប់ដោយធ្វើតាមការណែនាំងាយៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ<br>- ប្រាប់ពីសកម្មភាពតាមដំណាក់ដោយអនុវត្តតាមការណែនាំ<br>- ប្រាប់ពីសូរសំឡេងផ្សេងៗក្នុងបរិស្ថាន<br>- ប្រាប់បានពីចំនួនសូរសំឡេងដែលគោះឆ្លាស់គ្នា។<br>**បំណិនសម្បទា**<br>- រៀបរូបភាព និងរៀបរាប់តាមដំណើររឿងដែលបានបង្ហាញ<br>- ធ្វើសកម្មភាពតាមការណែនាំ៣ដំណាក់ដូចជា យកពែងនៅលើតុទៅដាក់កន្លែងលាង រួចដើរមកទីនេះវិញ<br>- ឆ្លើយតបនឹងសំណួរសាមញ្ញៗយ៉ាងតិច ៣សំណួរ<br>- បង្ហាញបានពីសូរសំឡេងនានា ក្នុងបរិស្ថាន<br>- រៀបរាប់បានពីចំនួនសូរសំឡេង ដែលបានគោះឆ្លាស់គ្នាដូចជា គោះចំនួន ១ គោះចំនួន ៣ គោះចំនួន ២ ជាដើម។ | ១២ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ស្តាប់ការនិទានរឿងដោយសប្បាយរីករាយ<br>- គោរពតាមការណែនាំដោយការពេញចិត្ត ។ | |
| **ការសន្ទនា** | សន្ទនាដោយប្រើពាក្យ ឬឃ្លាសមស្របតាមវ័យ(ភាសាបង្ហាញអារម្មណ៍ និងមនោសញ្ចេតនា) | **វិជ្ជាសម្បទា**<br>- ប្រាប់ពីសកម្មភាពការងារនានា ដែលខ្លួនបានធ្វើកន្លងមកទៅកាន់មិត្តភក្តិ ឬមនុស្សធំ។<br>**បំណិនសម្បទា**<br>- សន្ទនាពីសកម្មភាពការងារនានា ដែលខ្លួនបានធ្វើកន្លងមក ទៅមិត្តភក្តិ ឬមនុស្សធំ ដោយប្រើពាក្យ ឬឃ្លាបានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយក្នុងការសន្ទនាតាមការណែនាំ<br>- បង្ហាញឥរិយាបថសមរម្យ រង់ចាំវេនដើម្បីនិយាយ និងចូលរួមក្នុងការសន្ទនា ។ | ៩ ម៉ |
| **ការប្រើពាក្យតាមទេយ្យាករណ៍** | ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះសត្វ ឬវត្ថុនានាដែលធ្លាប់ស្គាល់ចំនួន ៥ ឬលើសពីនេះ<br>- ប្រាប់បានពីពាក្យ ឬឃ្លា ដែលទាក់ទងនឹងសម្ភារៈ ប្រើប្រាស់ ប្រចាំថ្ងៃ និងសកម្មភាពចាំបាច់មួយចំនួន។<br>**បំណិនសម្បទា**<br>- រៀបរាប់ឈ្មោះសត្វ និងវត្ថុនានាដែលធ្លាប់ស្គាល់ចំនួន ៥ ឬលើសពីនេះ<br>- ប្រើពាក្យ ឬឃ្លា បានត្រឹមត្រូវទៅតាមស្ថានភាពមនុស្សធំដែលមានចំនួនព្យាង្គពី ៥ ទៅ៦ ឬលើសពីនេះដូចជា ពុកម៉ែពិសាបាយ  ម៉ែគាត់កំពុងសម្រាន្តជាដើម។<br>**ចរិយាសម្បទា**<br>- ទម្លាប់និយាយពាក្យ ឬឃ្លា បានត្រឹមត្រូវដោយមានភាពជឿជាក់លើខ្លួនឯង។ | ១២ ម៉ |
| **ប្រើពាក្យសម្តីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង** | ទំនាក់ទំនងដោយ ប្រើពាក្យសម្តី | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីចំណងជើងរឿង និងអត្ថន័យរឿងតាមរូបភាព<br>- ប្រាប់បានពីសកម្មភាពដែលខ្លួនពេញចិត្តក្រោយពីស្តាប់រឿងនិទានរួច ។<br>**បំណិនសម្បទា**<br>- និទានរឿងតាមរូបភាពឱ្យអ្នកដទៃស្តាប់<br>- និយាយពីសកម្មភាពដែលខ្លួនពេញចិត្តក្រោយពីស្តាប់ រឿងនិទានរួច និងឈានទៅរកវិភាគតួអង្គ។ | ១២ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- មានទម្លាប់ប្រើពាក្យសម្ដីទំនាក់ទំនងទៅវិញទៅមក ។ | |
| | **ទំនាក់ទំនងដោយប្រើកាយវិការ និងនិមិត្តសញ្ញា** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីនិមិត្តសញ្ញាសាធារណៈទៅអ្នកដទៃចំនួន ៣ ដូចជា៖ បន្ទប់ទឹកស្រី បន្ទប់ទឹកប្រុស និងសញ្ញាពេទ្យ។<br>**បំណិនសម្បទា**<br>- ធ្វើកាយវិការ និងបង្ហាញនិមិត្តសញ្ញាសាធារណៈទៅអ្នកដទៃចំនួន៣ បន្ទប់ទឹកស្រី បន្ទប់ទឹកប្រុស និងសញ្ញាពេទ្យ ។<br>**ចរិយាសម្បទា**<br>- ឈ្លាសវៃក្នុងការទំនាក់ទំនងជាមួយដៃគូ ឬក្រុមរបស់ខ្លួននៅពេលសម្ដែងកាយវិការ និងបង្ហាញនិមិត្តសញ្ញា។ | ៨ ម៉ |
| | **និមិត្តសញ្ញាតំណាងឱ្យមនុស្ស សត្វ ឬវត្ថុនានា** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឈ្មោះមនុស្ស សត្វ វត្ថុ ឱ្យបានចំនួន ៣ តាមរយៈការធ្វើចលនាត្រាប់តាមនិមិត្តសញ្ញា។<br>**បំណិនសម្បទា**<br>- បង្ហាញនិមិត្តសញ្ញាមួយឱ្យកុមារធ្វើចលនាត្រាប់តាម និងប្រាប់ឈ្មោះមនុស្ស សត្វ ឬវត្ថុបានចំនួន៣។<br>**ចរិយាសម្បទា**<br>- សម្ដែងនូវអារម្មណ៍សប្បាយរីករាយក្នុងការបង្ហាញ និងប្រាប់ឈ្មោះ សត្វ វត្ថុដែលបានរកឃើញ។ | ៨ ម៉ |
| **ការស្គាល់តួអក្សរ** | **ការប្រើញាណរបស់ខ្លួនដើម្បីអភិវឌ្ឍបំណិនសមត្ថភាពទាំង ៦** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះសត្វ  វត្ថុផ្សេងៗចំនួន៣ ដោយស្ដាប់សំឡេង ឬ សង្កេតកាយវិការ<br>- ប្រាប់បានពីរបៀបលេងល្បែងបុរសំណេរ។<br>**បំណិនសម្បទា**<br>- បង្ហាញឈ្មោះសត្វ ឬវត្ថុផ្សេងៗតាមការស្ដាប់សំឡេង ឬការសង្កេតកាយវិការ<br>- អនុវត្តល្បែងបុរសំណេរដោយប្រើបំណិនសមត្ថភាពទាំង ៦។<br>**ចរិយាសម្បទា**<br>- មានចំណូលចិត្ត និងសប្បាយរីករាយក្នុងពេលលេងល្បែងបុរសំណេរ។ | ១៥ ម៉ |
| | **ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង និងស្សូត្រ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីទិសនៃសូរសំឡេងសត្វ ឬវត្ថុនានានៅក្នុងបរិស្ថាន<br>- ប្រាប់ពីចំណងជើង និងអត្ថន័យនៃកំណាព្យ។ | ២០ ម៉ |

| | | | |
|---|---|---|---|
| | កំណាព្យ | **បំណិនសម្បទា**<br>- បង្ហាញភាពខុសគ្នាខ្លះៗនៃសូរសំឡេងមួយចំនួនទៅតាមទិស<br>- សូត្រកំណាព្យត្រូវតាមវាក្យស័ព្ទ និងលំនាំបទ។<br>**ចរិយាសម្បទា**<br>-មានបម្រុងប្រយ័ត្នក្នុងការស្ដាប់ និងចូលចិត្តសូត្រកំណាព្យ។ | |
| | ការយល់ដឹងអំពីបញ្ញត្តិនៃសំណេរ | **វិជ្ជាសម្បទា**<br>-ប្រាប់បានពីរបៀបគូសគំនូរផ្សេងៗដូចជាគូសពីលើចុះក្រោម ពីឆ្វេងទៅស្ដាំជាដើម<br>-ប្រាប់បានពីរបៀបរៀបវត្ថុតូចៗតាមរាងផ្សេងៗ ឬរូបភាពដោយគោរពតាមទិសនៃសំណេរ ។<br>**បំណិនសម្បទា**<br>-រៀបវត្ថុតូចៗតាមរាងផ្សេងៗ ឬរូបដោយគោរពតាមទិសនៃសំណេរ<br>-គូសគំនូសផ្សេងៗដូចជាគូសពីលើចុះក្រោម ពីឆ្វេងទៅស្ដាំជាដើម។<br>**ចរិយាសម្បទា**<br>-មានភាពផ្ចិតផ្ចង់ក្នុងការរៀបវត្ថុតូចៗលើគំនូរផ្សេងៗ។ | ១២ ម៉ |
| | ការយល់ដឹង និងពេញចិត្តអំពីការអាន និងការប្រើប្រាស់ឯកសារសំណេរ ឬឯកសារផ្សេងៗ | **វិជ្ជាសម្បទា**<br>-ប្រាប់ពីរបៀបបើកសៀវភៅរឿងនិទានពី ឆ្វេងទៅ ស្ដាំមិនរំលង ទំព័រ និងអានតាមរូបភាព<br>-ប្រាប់បានពីដំណើររឿងក្នុងសៀវភៅរឿងនិទាន។<br>**បំណិនសម្បទា**<br>-អានរឿងតាមរូបភាពដោយបើកទំព័រសៀវភៅត្រឹមត្រូវតាមលំដាប់លំដោយ<br>-រៀបរាប់បានពីដំណើររឿងក្នុងសៀវភៅរឿងនិទាន។<br>**ចរិយាសម្បទា**<br>-មានទម្លាប់ល្អក្នុងការប្រើប្រាស់ និងថែរក្សាសៀវភៅ។ | ១២ ម៉ |
| **គូស និងសរសេរតួអក្សរ** | បំណិនសំណេរកាន់តែប្រសើរឡើង | **វិជ្ជាសម្បទា**<br>-ប្រាប់ពីរបៀបគូសបំពេញរូបគំនូរដែលមានរាងងាយៗបាន។<br>**បំណិនសម្បទា**<br>-គូសបំពេញរូបគំនូរដែលមានរាងងាយៗបានតាមស្នាមចុច។<br>**ចរិយាសម្បទា**<br>-ចូលចិត្ត និងមានបម្រុងប្រយ័ត្នក្នុងការកាន់ខ្មៅដៃគូសភ្ជាប់។ | ២០ ម៉ |

## ៧.៣- កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាកម្រិតខ្ពស់ (កុមារអាយុ៥ឆ្នាំ)

### មុខវិជ្ជា ៖ ចិត្តចលភាព (២១០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **ចំណិនចលករតូច** | ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។<br>**បំណិនសម្បទា**<br>- កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ។<br>**ចរិយាសម្បទា**<br>- មានអំណត់ តស៊ូព្យាយាម និងសប្បាយរីករាយក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ និងជោគជ័យ។ | ៣៥ ម៉ |
| **ចំណិនចលករធំ** | ការហ្វឹកហាត់បង្កើនកម្លាំង និងការសម្របសម្រួលនៃចលនាសាច់ដុំតូច និងសាច់ដុំធំ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីរបៀបដើរ រត់ វារលូន លោត ចុះនិងឡើង បោះ តោង ឡើងគប់ ប្រមៀល បង្វិលខ្លួន រុញ និងទាញ ទៅតាមគោលដៅ និងចម្ងាយដែលបានកំណត់ ។<br>**បំណិនសម្បទា**<br>- ដើរទប់ខ្លួនឱ្យមានលំនឹងលើគំនូសខ្សែ ឬកាន់វត្ថុនានានៅនឹងដៃ<br>- រត់នៅមួយកន្លែង រត់យឺត រត់លឿន<br>- វារលូន ប្រមៀលខ្លួន លើកន្ទេល កម្រាលឥដ្ឋសំបកកង់<br>- គប់ចម្ងាយ គប់ចំចំណុច តោងឡើងរបារ បង្វិលខ្លួនលើដី និងជុំវិញរបស់ណាមួយរុញ និងទាញដោយប្រើរាងកាយ<br>- ដើរកាន់កែវគ្មានដៃ ដែលមានចំណុះទឹក ៣/៤ ដោយប្រើដៃម្ខាង មិនឱ្យទឹកកំពប់ក្នុងចម្ងាយ ៥ ម៉ែត្រ ឬលើសពីនេះ<br>- លោតខ្សែអន្ទាក់ជើងពីរដោយខ្លួនឯងចំនួន ៣ជុំ ឬលើសពីនេះ<br>- ឡើង និងចុះតាមជណ្ដើរខ្សែព្យួរ កម្ពស់ ២ម៉ែត្រ ឬលើសពីនេះ<br>- បោះបាល់ចំនួន ៣ដង ដោយដៃទាំងពីរ ចូលទៅក្នុង ផ្ទាំងក្រដាសរាងការេ ទំហំ ៣០សម x ៣០សម ក្នុងចម្ងាយ ៣ម៉ែត្រ ឬលើសពីនេះ។ | ៣៥ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- សប្បាយរីករាយ និងចូលចិត្តធ្វើចលនាប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ។ | |
| **ការរីកចម្រើនរាងកាយនិងចលនា** | ការបង្កើនកម្លាំង និងការប្រឈមទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព | **វិជ្ជាសម្បទា**<br>- បង្ហាញពីរបៀបដើរ រត់ លោត ឬលើសពីនេះ ទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពមួយ។<br>**បំណិនសម្បទា**<br>- អនុវត្តសកម្មភាពមួយបានទន់ភ្លន់ រហ័សរហួន និងរឹងមាំដោយការផ្តើមចេញពីចលនាមូលដ្ឋានងាយៗទៅលំបាកចំនួន ២ ឡើងទៅ ក្នុងនោះមានការដើរ រត់ លោត ឬលើសពីនេះ តាមរយៈចលនាចរន្ត ហាត់ប្រាណតាមរឿងនិទាន តាមបទចម្រៀង តាមបទភ្លេង និងល្បែងចលនា។<br>**ចរិយាសម្បទា**<br>- ក្លាហាន ជឿជាក់លើសមត្ថភាព និងកម្លាំងរបស់ខ្លួនថាមានសុវត្ថិភាពក្នុងពេលធ្វើសកម្មភាពឆ្លងកាត់ឧបសគ្គ ។ | ១៨០ ម៉ |

## មុខវិជ្ជា ៖ វិទ្យាសាស្ត្រ (១០៥ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **អាហារូបត្ថម្ភ** | ចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះបន្លែ ផ្លែឈើ និងអាហារ ៣ក្រុម<br>- ប្រាប់បានពីសារៈសំខាន់នៃការញុំាអាហារផ្សេងៗ បន្លែ ផ្លែឈើ និងសាច់<br>-ប្រាប់បានពីអាហារគ្មានគុណភាព និងមានគុណភាព។<br>**បំណិនសម្បទា**<br>- ញែកបានពីអាហារ ៣ក្រុមដែលមានក្រុមអាហារការពារ ក្រុមអាហារសាងសង់ និងក្រុមអាហារថាមពល<br>- បង្ហាញពីអាហារដែលមានគុណភាព គ្មានគុណភាពនិងសារៈសំខាន់នៃការញុំាអាហារបន្លែ ផ្លែឈើ និងសាច់។<br>**ចរិយាសម្បទា**<br>- ចូលចិត្តញុំាបន្លែ ផ្លែឈើ និងអាហារសម្បូរជីវជាតិ<br>- សហការ ស្តាប់យោបល់ និងឯកភាពដើម្បីសម្រេចការងារក្រុម។ | ១៨ ម៉ |

| | | | |
|---|---|---|---|
| **បំណិនអនាម័យ** | **ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីទម្លាប់ល្អទាំងឡាយ មុន និងក្រោយពេលញ៉ាំ អាហារ បន្លែ ផ្លែឈើ ចូលបង្គន់អនាម័យ និងពេលបានប៉ះពាល់របស់កខ្វក់ សម្អាតខ្លួនប្រាណ សម្ភារៈផ្ទាល់ខ្លួន និង សម្ភារៈលេងផ្សេងៗ<br>- ប្រាប់ពីទីកន្លែងទុកដាក់សំរាមតាមការកំណត់<br>- ប្រាប់ពីវិធីការពារក្នុងពេលក្អក កណ្តាស់ និងសម្អាតច្រមុះ<br>-ប្រាប់ពីអាហារ បន្លែ ផ្លែឈើ និងសាច់ គួរញ៉ាំ ឬមិនគួរញ៉ាំ<br>- ប្រាប់បានពីរបៀបធ្វើអនាម័យ បន្លែ ផ្លែឈើ ទឹក មុននឹងញ៉ាំ។<br>**បំណិនសម្បទា**<br>- លាងសម្អាតដៃតាមពេលវេលាដូចជា មុននិងក្រោយពេលញ៉ាំអាហារ ក្រោយចេញពីបង្គន់ និងពេលបានប៉ះពាល់របស់កខ្វក់<br>- ចោលសំរាមទៅក្នុងធុងសំរាម<br>- ខ្ទប់មាត់ពេលក្អក កណ្តាស់ និងសម្អាតច្រមុះពេលហៀរសំបោរ។<br>- អនាម័យល្អមុនពេលញ៉ាំអាហារ បន្លែ ផ្លែឈើ ទឹកស្អាត<br>- ងូតទឹក ដុសធ្មេញ សិតសក់ សម្អាតដៃជើង ស្លៀកពាក់ខ្លួនឯង<br>- បង្ហាញពីអាហារ បន្លែ ផ្លែឈើ និងសាច់ ដែលគួរញ៉ាំ ឬមិនគួរ ញ៉ាំ និងរបៀបដែលអាចធ្វើឱ្យញ៉ាំបាន<br>- សំអាតសម្ភារៈផ្ទាល់ខ្លួន និងសម្ភារៈលេងផ្សេងៗ។<br>**ចរិយាសម្បទា**<br>- មានទម្លាប់ល្អក្នុងការធ្វើអនាម័យខ្លួនឯងជាប្រចាំដោយការហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។ | ៩ ម៉ |
| **ប្រតិបត្តិដោយសុវត្ថិភាព** | **ការយល់ដឹងពីការប្រតិបត្តិខ្លួន ដើម្បីសុវត្ថិភាព** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីវត្ថុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដូចជា៖ ភ្លើង អគ្គិសនី  ថ្នាំសម្លាប់សត្វល្អិត ថ្នាំពេទ្យ ស្លាកសញ្ញាមីន សញ្ញាចរាចរ វត្ថុមុតស្រួច ទឹកពាង និងស្រះទឹក<br>- ប្រាប់បានពីអាសយដ្ឋាន ឈ្មោះឪពុកម្តាយ ឬអ្នកនៅផ្ទះជាមួយ ឬ អ្នកស្គាល់ ដើម្បីឱ្យគេជួយនៅពេលមានបញ្ហា។<br>**បំណិនសម្បទា**<br>- បង្ហាញពីឈ្មោះឪពុកម្តាយ អ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់ និង អាសយដ្ឋានរបស់ខ្លួននៅពេលវង្វេងផ្លូវ | ៩ ម៉ |

| | | | |
|---|---|---|---|
| | | - រៀបរាប់បានពីគ្រោះថ្នាក់ដែលបណ្តាលមកពី ការលេងភ្លើង អគ្គិសនី ថ្នាំសម្លាប់ សត្វល្អិត ថ្នាំពេទ្យ ស្លាកសញ្ញាមីន សញ្ញាចរាចរ វត្ថុមុតស្រួច ទឹកពាង ឬស្រះទឹក... ។<br>**ចរិយាសម្បទា**<br>- ក្លាហាន មិនតក់ស្លុតក្នុងការប្រាប់ឈ្មោះឪពុកម្តាយ អ្នកនៅក្នុងផ្ទះជាមួយ ឬអ្នកស្គាល់ នៅពេលវង្វេងផ្លូវ ។<br>- ចៀសវាងសកម្មភាពមួយចំនួនដែលនាំឱ្យមានគ្រោះថ្នាក់ ការលេងតាមចិញ្ចើមថ្នល់ និងមនុស្ស មិនស្គាល់មុខ។ | |
| **ការរស់នៅប្រចាំថ្ងៃ** | **ការស្វែងយល់ដោយការសង្កេត** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះ លក្ខណៈ រូបផ្តុំ ចរិតលក្ខណៈ របស់សត្វចិញ្ចឹម សត្វព្រៃ សត្វស្លាបឬលើសពីនេះ<br>- ប្រាប់បានពីរបៀបនៃការពិសោធ និងស្វែងយល់ពីបរិស្ថាន។<br>**បំណិនសម្បទា**<br>- រៀបរាប់ឈ្មោះសត្វចិញ្ចឹម សត្វព្រៃ សត្វស្លាប ចរិតលក្ខណៈ លក្ខខណ្ឌរស់នៅ វដ្តនៃសត្វ ការប្រៀបធៀបសត្វ និងផលប្រយោជន៍<br>- ពិសោធ និងស្វែងយល់ដោយប្រើសម្ភារៈផ្សេងៗ ក្នុងការលេងដូចជាលិច អណ្តែត ជ្រាបទឹក និងមិនជ្រាបទឹក វត្ថុរលាយនិងមិនរលាយ ការលាយពណ៌ បណ្តុះគ្រាប់ធញ្ញជាតិ ខ្យល់ជាដើម។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលចិត្តចិញ្ចឹម និងថែរក្សាសត្វ<br>- មានបម្រុងប្រយ័ត្នក្នុងការពិសោធ និងទុកដាក់សម្ភារៈឱ្យមានសណ្តាប់ធ្នាប់ និងមានសុវត្ថិភាព ។ | **១៥ ម៉** |
| | **អ្វីៗដែលគ្មានជីវិត និងមានជីវិត** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះអ្វីដែលគ្មានជីវិត និងមានជីវិត ។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីអ្វីដែលមានជីវិត និងគ្មានជីវិតដូចជា៖ សត្វ មនុស្ស រុក្ខជាតិ ទឹក ដី និងវត្ថុនានា ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ និងចូលរួមថែរក្សាអ្វីៗដែលមានជីវិត និងទ្រព្យសម្បត្តិសាធារណៈ។ | **៦ ម៉** |

| | | | |
|---|---|---|---|
| | លក្ខណៈមេឃ និងអាកាសធាតុ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអាកាសធាតុ រដូវប្រាំង និងរដូវវស្សា<br>- ប្រាប់បានពីផលលំបាកនៃបាតុភូតធម្មជាតិដូចជា៖ ភ្លៀង ផ្លេកបន្ទោរ រន្ទះ ផ្គរ ខ្យល់ ព្យុះ ទឹកជំនន់ រាំងស្ងួត។<br>**បំណិនសម្បទា**<br>- ញែកបានពីរដូវប្រាំង និងរដូវវស្សា<br>- បង្ហាញពីផលលំបាកនៃបាតុភូតធម្មជាតិ ដូចជា ៖ ភ្លៀង ផ្គរ រន្ទះ ផ្លេកបន្ទោរ ខ្យល់ ព្យុះ ទឹកជំនន់ រាំងស្ងួត។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្ន និងការពារខ្លួននៅពេលមានបាតុភូតធម្មជាតិ។ | ៦ ម៉ |
| | លក្ខណៈរូបធាតុ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវត្ថុដែលធ្វើអំពីឈើ ដែក ជ័រប្លាស្ទិច និងថ្មបានយ៉ាងតិច ៥ ឬលើសពីនេះ<br>- ប្រាប់បានពីភាពខុសគ្នារវាងវត្ថុធាតុដើមនៃសម្ភារៈដោយប្រើបញ្ញត្តិ ដូចជា៖ រឹង ទន់ គ្រើម រលោង សើមស្ងួត ក្តៅ ត្រជាក់ ។<br>**បំណិនសម្បទា**<br>- ញែកបានរវាងវត្ថុធ្វើអំពីឈើ ដែក ជ័រប្លាស្ទិច និងថ្ម<br>- ញែកបានពីភាពខុសគ្នារវាងវត្ថុធាតុដើមនៃសម្ភារៈដោយប្រើបញ្ញត្តិ ដូចជា៖ រឹង ទន់ គ្រើម រលោង ក្តៅត្រជាក់ សើមស្ងួត។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្នក្នុងការប្រើប្រាស់វត្ថុនានាចៀសវាងគ្រោះថ្នាក់ ។ | ៦ ម៉ |
| | អំពីរាងកាយផ្ទាល់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះផ្នែកផ្សេងៗ នៃរាងកាយរបស់មនុស្ស ។<br>**បំណិនសម្បទា**<br>- បង្ហាញពីផ្នែកផ្សេងៗ និងមុខងាររបស់រាងកាយមនុស្សដូចជាភ្នែកសម្រាប់មើល ត្រចៀកសម្រាប់ស្តាប់ មាត់សម្រាប់និយាយ និងញុំាបាយ ច្រមុះសម្រាប់ហិតក្លិន ដៃសម្រាប់ធ្វើការងារ ជើងសម្រាប់ដើរ និងមុខងារផ្នែកផ្សេងទៀត។<br>**ចរិយាសម្បទា**<br>- ចាប់អារម្មណ៍ពីការលូតលាស់របស់រាងកាយ ដូចជា៖ សក់ដុះវែង | ៦ ម៉ |

| | | | |
|---|---|---|---|
| | | ក្រចកលូតវែង ខ្លួនលូតកម្ពស់ជាដើម។ | |
| | **ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា** | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗ ដែលប្រើក្នុងផ្ទះប្រចាំថ្ងៃយ៉ាងតិចចំនួន ៤<br>- ប្រាប់បានពីឈ្មោះសំណង់សាមញ្ញៗ។<br>**បំណិនសម្បទា**<br>- បង្ហាញឈ្មោះឧបករណ៍បច្ចេកវិទ្យាសាមញ្ញៗដែលប្រើក្នុងជីវភាព ប្រចាំថ្ងៃ យ៉ាងតិចចំនួន៤ ដូចជា៖ ទូរទស្សន៍ វិទ្យុ កង្ហារ ទូរស័ព្ទជាដើម ។<br>- សាងសង់សំណង់សាមញ្ញៗដោយប្រើក្រដាស ដីឥដ្ឋ ឬដុំឈើ ឬដុំឥដ្ឋដូចជាធ្វើទូក កូនឡានជាដើម។<br>**ចរិយាសម្បទា**<br>- មានបម្រុងប្រយ័ត្នក្នុងការប៉ះពាល់ ឬធ្វើសកម្មភាព ប្រកប ដោយសុវត្ថិភាព ។ | **៦ ម៉** |
| | **មធ្យោបាយធ្វើដំណើរ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីមធ្យោបាយធ្វើដំណើរ ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីឈ្មោះ ទ្រង់ទ្រាយ និងផលប្រយោជន៍របស់មធ្យោបាយធ្វើដំណើរនីមួយៗបានត្រឹមត្រូវ ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលរួមរក្សាផលប្រយោជន៍របស់មធ្យោបាយធ្វើដំណើរនីមួយៗ ។ | **៦ ម៉** |
| **បំណិនពិចារណា** | **ការយល់ដឹងពីហេតុ និងផល** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីលក្ខណៈរបស់អាកាសធាតុ ស្ថានភាពមុន កំពុង និងក្រោយពេលមានភ្លៀង ដូចជា មេឃងងឹត ផ្គរលាន់ ផ្លេកបន្ទោរ ខ្យល់ជាដើម<br>- ប្រាប់បានពីមូលហេតុដែលធ្វើឱ្យវត្ថុប្រែប្រួល<br>- ប្រាប់បានពីសកម្មភាពដែលជះឥទ្ធិពលលើវត្ថុនានា ដូចជា៖ ចាន ថូ កែវ ធ្លាក់លើកម្រាលវានឹងបែកជាដើម ។<br>**បំណិនសម្បទា**<br>- ទាយទុកនូវបាតុភូតនានាដូចជា៖ អាចនឹងមានភ្លៀងពេលឃើញ | **៩ ម៉** |

| | | | |
|---|---|---|---|
| | | មេឃងងឹត ឮផ្គរលាន់ មានខ្យល់ និងឃើញផ្លេកបន្ទោរ<br>- រៀបរាប់ពីព្រឹត្តិការណ៍មុន កំពុង និងក្រោយពេលភ្លៀងធ្លាក់<br>- បញ្ជាក់បានពីសកម្មភាពដែលជះឥទ្ធិពលលើវត្ថុនានាដូចជា៖ ចាន ថូ កែវ ធ្លាក់លើកម្រាលវានឹងបែកជាដើម ។<br>**ចរិយាសម្បទា**<br>- ប្រុងប្រយ័ត្នមុនពេលភ្លៀង ពេលកំពុងភ្លៀង និងក្រោយភ្លៀង និងការប្រើប្រាស់វត្ថុនានា។ | |
| **បំណិនក្នុងសង្គម** | ចំណេះដឹងអំពីសហគមន៍ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះសម្ភារៈតាមមុខរបរនៅក្នុងមូលដ្ឋានរស់នៅ<br>- ប្រាប់បានពីឈ្មោះ និងមុខងារនៃទីកន្លែងសំខាន់ៗក្នុងភូមិ។<br>**បំណិនសម្បទា**<br>- បង្ហាញពីមុខងារសម្ភារៈតាមមុខរបរដូចជា កន្ត្រៃ ស្និតសិតសក់ កាំបិតកោរ...សម្រាប់ប្រើក្នុងមុខរបរកាត់សក់<br>- បង្ហាញពីមុខងារទីកន្លែងសំខាន់ៗក្នុងភូមិ ដូចជា៖ សាលារៀន វត្តអារាម ផ្សារ មណ្ឌលសុខភាព។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់មុខរបរសុចរិត និងមោទកភាពចំពោះភូមិ ឃុំខ្លួន ។ | ៩ ម៉ |

## មុខវិជ្ជា ៖ សិក្សាសង្គម (៤៩០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **ការយល់ដឹងពីតម្លៃមនុស្ស** | ការយល់ដឹងពីតម្លៃ និងចរិត លក្ខណៈមនុស្ស | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអំពើមិនល្អ និងអំពើល្អ( បុណ្យ បាប )<br>- ប្រាប់បានពីការគោរពចាស់ទុំ។<br>**បំណិនសម្បទា**<br>- គោរព និងឱ្យតម្លៃចំពោះអ្នកដទៃដូចជា៖បាទ ចាស ខ្ញុំ អរគុណ សូមទោស ជម្រាបសួរ ជម្រាបលា ដើរឱនៗ និងមិនសើចចំអក<br>- បង្ហាញពីសកម្មភាពដែលជាទង្វើល្អ និងទង្វើមិនល្អ។<br>**ចរិយាសម្បទា**<br>- សម្តែងអាកប្បកិរិយាគោរពអ្នកដទៃបានត្រឹមត្រូវ<br>- គោរពវេនលេងល្បែងដោយមិនបង្កទំនាស់ មានសាមគ្គីភាព និងជួយដោះស្រាយបញ្ហាគ្នា។ | ៥ ម៉ |

| | | | |
|---|---|---|---|
| **ការលើកតម្កើងវប្បធម៌** | ការលើកតម្កើងវប្បធម៌របស់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីសកម្មភាពខ្លះៗរបស់បុណ្យប្រពៃណីជាតិខ្មែរ បុណ្យចូលឆ្នាំខ្មែរ បុណ្យអុំទូក បុណ្យភ្ជុំបិណ្ឌ និងការគោរពចាស់ព្រឹទ្ធាចារ្យ ព្រះបដិមា និងព្រះសង្ឃ<br>- ប្រាប់បានពីទង់ជាតិរបស់ប្រទេសកម្ពុជា និងទង់សាសនា<br>- ប្រាប់បានពីសម្លៀកបំពាក់ប្រពៃណីខ្មែរ និងឧបករណ៍ ភ្លេងខ្មែរ<br>- ប្រាប់បានពីទីកន្លែងសំខាន់ៗមួយចំនួន ដូចជា៖ អង្គរវត្ត វត្តអារាម ព្រះបរមរាជវាំង (ឬទីកន្លែងតាមតំបន់)។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីអត្ថន័យ និងសកម្មភាពសំខាន់ៗក្នុងពិធីបុណ្យប្រពៃណីជាតិខ្មែរដូចជា៖ បុណ្យអុំទូក បុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ<br>- បង្ហាញពីសម្ភារៈប្រើប្រាស់ដែលជាប្រពៃណីរបស់ជនជាតិខ្មែរដូចជា៖ ហូល ផាមួង អាវប៉ាក់ ក្រមា សារុងសូត្រ អាវបំពង់វែង ក្បិន ស្គរ ខ្លុយ រនាត ចាប៉ី ...<br>- បង្ហាញពីទង់ជាតិរបស់ប្រទេសកម្ពុជា និងទង់សាសនា<br>- ច្រៀងបទគោរពទង់ជាតិ (បទនគររាជ) បានត្រឹមត្រូវ តាម ទំនុកបទបានចំនួន ៣ វគ្គ ។<br>**ចរិយាសម្បទា**<br>- សំពះនៅពេលឃើញចាស់ព្រឹទ្ធាចារ្យ ព្រះបដិមា ព្រះសង្ឃ និងក្នុងពេលសូត្រធម៌<br>- យកចិត្តទុកដាក់ចូលរួមគោរពទង់ជាតិបានទៀងទាត់។ | ១៥ ម៉ |
| **បំណិនទំនាក់ទំនង** | អត្តសញ្ញាណរបស់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីនាមត្រកូល នាមខ្លួន ចំនួនសមាជិកក្នុងគ្រួសារ និងជាកូនទីប៉ុន្មាន ។<br>**បំណិនសម្បទា**<br>- ណែនាំនាមត្រកូល និងនាមខ្លួន<br>- រាប់ចំនួនសមាជិកក្នុងគ្រួសារ ចំនួនបងប្អូន និងខ្លួនឯងជាកូនទីប៉ុន្មាន។<br>**ចរិយាសម្បទា**<br>- ជឿជាក់ក្នុងការណែនាំខ្លួន ចំនួនសមាជិកក្នុងគ្រួសារដល់អ្នកដទៃ | ៥ ម៉ |

| | | | |
|---|---|---|---|
| | | និងជាកូនទីប៉ុន្មាន។ | |
| | បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីឈ្មោះមនុស្សជុំវិញ និងអាសយដ្ឋានរបស់ខ្លួនឱ្យគេជួយនៅពេលមានបញ្ហា<br>- ប្រាប់ពីការងារងាយៗមួយចំនួនដូចជា ការឱ្យចំណីសត្វ ស្រោចដំណាំ  បោសសំអាត  ការងារផ្ទះបាយជាដើម ។<br>**បំណិនសម្បទា**<br>- រៀបរាប់ឈ្មោះមនុស្សជុំវិញ និងអាសយដ្ឋានរបស់ខ្លួនឱ្យអ្នកដែលបានជួយនៅពេលដែលខ្លួនមានបញ្ហា<br>- ជួយការងារមនុស្សធំ ដូចជា ការឱ្យចំណីសត្វ ស្រោចដំណាំ សម្អាតផ្ទះ ការងារផ្ទះបាយជាដើម។<br>**ចរិយាសម្បទា**<br>- ក្លាហានក្នុងការទាក់ទងជាមួយមនុស្សធំនៅពេលមានបញ្ហា<br>- មានទម្លាប់ជួយការងារស្រាលៗទៅតាមកម្លាំង ។ | ៥ ម៉ |
| | បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងល្អជាមួយមិត្តភក្តិដែលមានវ័យប្រហាក់ប្រហែលគ្នា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវត្តមាន អវត្តមានមិត្តភក្តិ កាលបរិច្ឆេទ និងទម្លាប់ល្អ<br>- ប្រាប់ពីរបៀបលេងល្បែងសេរីដែលបានលេងជាបុគ្គល ឬក្រុម<br>- ប្រាប់បានពីឈ្មោះកុមារដទៃទៀតដែលខ្លួនបានលេងជាមួយដោយមិនបំពានលើគ្នាទៅវិញទៅមក។<br>**បំណិនសម្បទា**<br>- បង្ហាញពីវត្តមាន អវត្តមានមិត្តភក្តិប្រចាំថ្ងៃ ឈ្មោះថ្ងៃ ខែ ឆ្នាំ ប្រចាំថ្ងៃ ដោយប្រើប្រាស់តារាងសកម្មភាពប្រចាំថ្ងៃ និងអនុវត្តទម្លាប់ល្អជាប្រចាំ<br>- លេងល្បែងសេរីដែលខ្លួនចូលចិត្តជាបុគ្គល ឬជាក្រុម<br>- ចូលរួមលេងជាមួយកុមារដទៃទៀតដោយមិនបំពានគ្នា<br>- បង្ហាញឈ្មោះកុមារដទៃទៀតដែលខ្លួនបានលេងជាមួយ។<br>**ចរិយាសម្បទា**<br>- គោរពពេលវេលាទៀងទាត់ និងមានទម្លាប់ល្អ<br>- បង្ហាញនូវស្មារតី ចែករំលែក និងការយោគយល់ក្នុងពេលលេងល្បែងជាមួយមិត្តភក្តិ ។ | ៣២០ ម៉ |

| | | | |
|---|---|---|---|
| | ការយល់ដឹងអំពីទង្វើ និងលទ្ធផល | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអំពើដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃ។<br>**បំណិនសម្បទា**<br>- ប្រព្រឹត្តអំពើទាំងឡាយណាដែលមិនប៉ះពាល់ដល់អ្នកដទៃ ។<br>**ចរិយាសម្បទា**<br>- ទម្លាប់ធ្វើអំពើល្អ និងគោរពទុកចិត្តអ្នកដទៃ ។ | ៥ ម៉ |
| | ការពេញចិត្តចំពោះលក្ខណៈផ្សេងគ្នារបស់បុគ្គល | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីលក្ខណៈសម្បត្តិរបស់មិត្តភក្តិដែលលេងជាមួយ<br>- ប្រាប់បានពីសមត្ថភាពមិត្តភក្តិដែលខ្លួនស្រឡាញ់ចូលចិត្ត។<br>**បំណិនសម្បទា**<br>- លេងជាមួយកុមារដទៃទៀតដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ រូបរាង ពិការ អ្នកមាន អ្នកក្រ...<br>- វាយតម្លៃបានត្រឹមត្រូវ និងគាំទ្រដោយភាពពេញចិត្តចំពោះសមត្ថភាពរបស់មិត្តភក្តិ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយក្នុងការលេងជាមួយកុមារដទៃទៀតដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ រូបរាង ពិការ អ្នកមាន អ្នកក្រ..។ | ៥ ម៉ |
| **ការយល់ដឹងអំពីខ្លួនឯង** | ស្គាល់ពីអារម្មណ៍មួយចំនួន | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអារម្មណ៍ និងមូលហេតុដែលធ្វើឱ្យខ្លួនសប្បាយ ត្រេកអរ ភ័យ ខ្លាចនៅពេលជួបព្រឹត្តិការណ៍ណាមួយ ។<br>**បំណិនសម្បទា**<br>- បង្ហាញកាយវិការ ឬនិយាយបានអំពីសេចក្តីស្រឡាញ់ និងទំនាក់ទំនងជាមួយមនុស្សដែលនៅជុំវិញ។<br>**ចរិយាសម្បទា**<br>- ទំនាក់ទំនងល្អទាំងកាយវិការ និងសម្តីប្រកបដោយសេចក្តីស្រឡាញ់ជាមួយមនុស្សដែលនៅជុំវិញ ។ | ៥ ម៉ |
| | សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់ពីអារម្មណ៍ និងគ្រប់គ្រងអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយធ្វើកាយវិការ<br>- ប្រាប់បានពីរបៀបសម្របខ្លួន និងទប់អារម្មណ៍មិនឱ្យឆាប់ខឹងទៅ | ៥ ម៉ |

| | | | |
|---|---|---|---|
| | | នឹងស្ថានភាពមនុស្សជុំវិញ។<br>**បំណិនសម្បទា**<br>- សម្ដែងអារម្មណ៍ផ្ទាល់ខ្លួន ខឹង ស្រឡាញ់ ស្អប់តាមរយៈកាយវិការ និងពាក្យសម្ដី<br>- សម្របខ្លួន និងទប់អារម្មណ៍ មិនឱ្យឆាប់ខឹងទៅនឹងស្ថានភាពមនុស្សជុំវិញ។<br>**ចរិយាសម្បទា**<br>- ទទួលស្គាល់បរាជ័យរបស់ខ្លួន និងភាពជោគជ័យរបស់ដៃគូលេងជាមួយ<br>- កែប្រែទម្លាប់អវិជ្ជមានដើម្បីរស់នៅក្នុងសង្គម។ | |
| **បំណិនពិចារណា** | គោលវិធីជាវិជ្ជមាន និងជំហរដើម្បីដោះស្រាយបញ្ហា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីវិធីដោះស្រាយបញ្ហាក្នុងក្រុម។<br>**បំណិនសម្បទា**<br>- បង្ហាញពីវិធីផ្សេងៗដើម្បីដោះស្រាយបញ្ហាលើសកម្មភាពមួយ ដូចជា ការរកវិធីផ្សេងៗដើម្បីយកបាល់ដែលនៅឆ្ងាយពីដៃ<br>**ចរិយាសម្បទា**<br>- សហការគ្នាល្អក្នុងការធ្វើការងារជាក្រុម ឬដៃគូ ។ | ៥ ម៉ |
| **បំណិនក្នុងសង្គម** | ការយល់ដឹងអំពីបរិស្ថានធម្មជាតិ និងវិធីការពារ | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះទីកន្លែងដែលមានបរិស្ថានធម្មជាតិល្អ និងទង្វើការពារបរិស្ថាន ដូចជាមិនចោលសំរាម និងមិនបន្ទោរបង់ ។<br>**បំណិនសម្បទា**<br>- រៀបរាប់ឈ្មោះទីកន្លែងដែលមានបរិស្ថានធម្មជាតិល្អ<br>- ជួយសម្អាតបរិស្ថានដូចជាការបោសសំរាម មិនបន្ទោរបង់ផ្ដេសផ្ដាសជាដើម។<br>**ចរិយាសម្បទា**<br>- ចូលចិត្តរស់នៅស្អាត  មានអនាម័យ និងស្រឡាញ់បរិស្ថាន។ | ៥ ម៉ |
| **គំនូរនិងសកម្មភាពគសាង** | ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបបត់ ឆោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់ ... ដើម្បីបង្កើតជារូបភាពផ្សេងៗ ។<br>**បំណិនសម្បទា**<br>- បត់ក្រដាសបានជារូបផ្សេងៗដូចជា៖ យន្តហោះ  ទូក  អាវ... | ៣៥ ម៉ |

| | | | |
|---|---|---|---|
| | | - សូនរូបបានជារាងងាយៗដោយប្រើដៃទាំង ២ដូចជា រូបសត្វ ឬផ្លែឈើជាដើម<br>- រោយ ដេរ ត្បាញ គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់ដើម្បីបង្កើតរូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលគេបានបង្កើត។<br>**ចរិយាសម្បទា**<br>- រហ័សរហួន និងប្រុងប្រយ័ត្នក្នុងការចាប់កាន់ បត់ សូន គូស ហែក កាត់ និងផាត់ពណ៌ ។ | |
| | **ការយល់ដឹងអំពីការឆ្លាស់វត្ថុតាមចង្វាក់ និងការគូរគំនូរ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបដោតអង្កាំ គូសគំនូស និងគំនូរ ។<br>**បំណិនសម្បទា**<br>- ដោតអង្កាំឆ្លាស់ពណ៌ចំនួន ៣ពណ៌តាមចង្វាក់<br>- គូសចម្លងតាមទ្រង់ទ្រាយរាងធរណីមាត្រដូចជា រង្វង់ រាងការេ ចតុកោណកែង និងត្រីកោណ លើក្រដាសឬលើដី<br>- គូររូបមនុស្សយ៉ាងតិចបាន ៦ផ្នែកខុសគ្នា រួមមាន ក្បាល ដងខ្លួន ដៃ ជើង ប្រអប់ដៃ និងប្រអប់ជើង។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយ និងទទួលស្គាល់សមិទ្ធផលការងាររបស់ខ្លួន។ | ៣៥ ម៉ |
| **ចម្រៀង និងតន្ត្រី** | **ចំណេះដឹងបច្ចេកទេស ចលនាការច្នៃប្រឌិត និងបទពិសោធន៍ផ្នែកតន្ត្រី** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីចំណងជើង និងអត្ថន័យនៃបទចម្រៀងមួយចំនួន របៀបធ្វើកាយវិការ និងរបៀបគោះសម្ភារៈនានាតាមចង្វាក់ភ្លេង<br>- ប្រាប់បានពីរបៀបរាំតាមចង្វាក់ប្រពៃណីខ្មែរដូចជា រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់<br>- ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារៈនានាតាមចង្វាក់ភ្លេង។<br>**បំណិនសម្បទា**<br>- ច្រៀងចម្រៀង និងធ្វើកាយវិការត្រូវតាមខ្លឹមសារបទចម្រៀង<br>- ទះដៃបន្ទរ ឬគោះសម្ភារៈនានា ត្រូវតាមចង្វាក់ភ្លេង<br>- រាំតាមចង្វាក់ប្រពៃណីខ្មែរ ដូចជា៖ រាំវង់  រាំក្បាច់ សារ៉ាវ៉ាន់...។<br>**ចរិយាសម្បទា**<br>- ស្រលាញ់ និងចូលចិត្តបទចម្រៀង កំណាព្យ និងរបាំប្រពៃណីខ្មែរ។ | ៤០ ម៉ |

**មុខវិជ្ជា ៖ មុរគេណិត (១០៥ ម៉ោង)**

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| **បរិមាណ និងចំនួន** | ស្គាល់ និងយល់លេខតាង និងការគណនាលេខសាមញ្ញៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីចំនួន លេខ និងយល់ន័យពី ១ ដល់ ៣០ តាមលំដាប់លំដោយ ឬលើសពីនេះ<br>- ប្រាប់បានពីរបៀបគូសចម្លងតាមលេខពី ១ ដល់ ២៥<br>- ប្រាប់បានពីរបៀបបន្ថែម និងដកចំនួនពី ១ដល់១៥ ឬលើសពីនេះ ដោយប្រើវត្ថុរូបី ។<br>**បំណិនសម្បទា**<br>- រាប់ចំនួន លេខ និងយល់ន័យពី ១ ដល់ ៣០ ឬលើសពីនេះ<br>- បន្ថែម និងដកចំនួនពី១ ដល់ ១៥ ឬលើសពីនេះ ដោយប្រើវត្ថុរូបី និងរាប់ចំនួនសរុប<br>- ប្រៀបធៀបចំនួនស្មើគ្នា តិចជាង ឬច្រើនជាងក្នុងចំនួនពី១ដល់១៥ ឬលើសពីនេះ<br>- គូសចម្លងតាមលេខពី ១ ដល់ ១៥ ឬលើសពីនេះ ។<br>**ចរិយាសម្បទា**<br>- ឈ្លាសវៃ រហ័សរហួនក្នុងការគិតលេខ។ | ៤០ ម៉ |
| | ការគិត និងវិភាគគ្រប់ជ្រុងជ្រោយ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីចំនួនរូបភាពចំនួនចំណុច និងលេខ ដែលត្រូវផ្គុំ និងផ្គូផ្គង។<br>**បំណិនសម្បទា**<br>- ផ្គុំ និងផ្គូផ្គងចំនួនរូបភាពទៅនឹងលេខ ចំនួនចំណុចទៅនឹងចំណុច ចំនួនចំណុចទៅនឹងលេខ។<br>**ចរិយាសម្បទា**<br>- ទម្លាប់គិត និងជឿជាក់ក្នុងការសម្រេចចិត្តបានត្រឹមត្រូវ ។ | ១៥ ម៉ |
| **ខ្វាស់ខ្វាល់** | បញ្ញត្តិស្ដីពីរង្វាស់រង្វាល់ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីបញ្ញត្តិ ខ្ពស់និងទាប វែងនិងខ្លី ធ្ងន់និងស្រាល ច្រើននិងតិច មាននិងមិនមាន ពេញនិងកន្លះ។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបខ្ពស់និងទាប វែងនិងខ្លី ធ្ងន់និងស្រាល ច្រើននិងតិច មាននិងមិនមាន ពេញនិងកន្លះ ដោយប្រើខ្នាត។ | ១២ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- សហការ និងព្យាយាមក្នុងការវាស់ វាល់ ថ្លឹង និងប្រៀបធៀប។ | |
| **រូបរាង និងលំហ** | បញ្ញត្តិនៃរូបរាង និងលំហ | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះរាងធរណីមាត្រសាមញ្ញៗ ដូចជារាងការេ ត្រីកោណ រង្វង់ និងចតុកោណកែងជាដើម<br>- ប្រាប់ពីទីតាំងវត្ថុមួយធៀបនឹងវត្ថុមួយផ្សេងទៀតដោយប្រើពាក្យ ដូចជា ខាងលើ ខាងក្រោម ខាងមុខ ខាងក្រោយ ខាងក្នុង ខាងក្រៅ ខាងឆ្វេង និងខាងស្តាំជាដើម។<br>**បំណិនសម្បទា**<br>- បង្ហាញរាងធរណីមាត្រសាមញ្ញៗ ដូចជា៖ រាងការេ ត្រីកោណ រង្វង់ និងចតុកោណកែងជាដើម<br>- កំណត់ទីតាំងវត្ថុធៀបទៅនឹងវត្ថុមួយដោយប្រើពាក្យដូចជាខាងលើ ខាងក្រោម ខាងមុខ ខាងក្រោយ ខាងក្នុង ខាងក្រៅ ខាងឆ្វេង និង ខាងស្តាំ។<br>**ចរិយាសម្បទា**<br>- សហការគ្នាក្នុងការអនុវត្តសកម្មភាពបានល្អ។ | ១២ ម៉ |
| **ទំហំ និងពណ៌** | ចំណាត់ក្រុម និងលំដាប់លំដោយ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីការរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌<br>- ប្រាប់បានពីរបៀបរៀបតាមចង្វាក់ដដែលៗនូវរូបរាង ធរណីមាត្រ តាមពណ៌បន្តគ្នា និងតាមលំដាប់លំដោយ។<br>**បំណិនសម្បទា**<br>- រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌<br>- រៀបរាងធរណីមាត្រ ឬពណ៌ ឬទំហំ ឬវត្ថុឱ្យត្រូវតាមចង្វាក់ ដដែលៗ ។<br>**ចរិយាសម្បទា**<br>- ទម្លាប់ប្រើប្រាស់ និងទុកដាក់សម្ភារៈឱ្យមានសណ្តាប់ធ្នាប់ ។ | ១២ ម៉ |
| **បំណិនពិចារណាក្នុងសង្គម** | ភាពខុសគ្នារវាងព្រឹត្តិការណ៍ដែលកើតឡើងក្នុង អតីតកាល បច្ចុប្បន្នកាល | **វិជ្ជាសម្បទា**<br>- ប្រាប់ពីពេលដែលកន្លងហួស កំពុង និងមិនទាន់ដល់<br>- ប្រាប់ពីឈ្មោះថ្ងៃក្នុងសប្តាហ៍តាមលំដាប់ដូចជាថ្ងៃអាទិត្យ ចន្ទ ...<br>- ប្រាប់បានពីពេលវេលាតាមលំដាប់លំដោយដូចជា ពេលព្រឹក ពេល | ៨ ម៉ |

| | | | |
|---|---|---|---|
| | និងអនាគតកាល (ដោយផ្តោតលើពេលវេលា) | ថ្ងៃត្រង់ និងពេលយប់ និងបញ្ញត្តិ មុន បន្ទាប់ ចុងក្រោយជាដើម<br>**បំណិនសម្បទា**<br>- រាប់ឈ្មោះថ្ងៃនៅក្នុងសប្តាហ៍តាមលំដាប់ដូចជាថ្ងៃអាទិត្យ ចន្ទ ដល់ សៅរ៍ជាដើម<br>- កំណត់ពេលវេលា រវាងថ្ងៃម្សិលមិញ ថ្ងៃនេះ និងថ្ងៃស្អែក អ្វីដែលបានធ្វើ អ្វីដែលកំពុងធ្វើ អ្វីដែលនឹងត្រូវធ្វើ<br>- រៀបរាប់ និងបង្ហាញរូបភាព ព្រឹត្តិការណ៍តាមលំដាប់លំដោយពេលវេលា ដូចជា ពេលព្រឹក ពេលថ្ងៃត្រង់ និងពេលយប់ និងបញ្ញត្តិ មុន បន្ទាប់ និងចុងក្រោយជាដើម។<br>**ចរិយាសម្បទា**<br>- មានទម្លាប់អនុវត្តសកម្មភាពប្រចាំថ្ងៃបានទៀងទាត់។ | |
| | ចំណេះដឹងនៃការប្រើប្រាស់រូបិយប័ណ្ណមួយចំនួន | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះនិងប្រភេទប្រាក់រៀលរបស់ខ្មែរដូចជាក្រដាស ៥០៛ ១០០៛ ២០០៛ ៥០០៛ ១ ០០០៛ ២ ០០០៛ និង ៥ ០០០៛ ។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់ប្រាក់រៀលតាមតម្លៃសម្រាប់ទិញនំ និងវត្ថុផ្សេងៗ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ និងឱ្យតម្លៃប្រាក់រៀលរបស់ជាតិខ្មែរ ។ | ៦ ម៉ |

## មុខវិជ្ជា ៖ ភាសាខ្មែរ (១៤០ ម៉ោង)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលសិក្សា | ម៉ោង |
|---|---|---|---|
| **ការស្តាប់** | ស្តាប់គេនិយាយ និងមានសមត្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ | **វិជ្ជាសម្បទា**<br>- ប្រាប់បានខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ<br>- ប្រាប់បានពីសកម្មភាពតាមដំណាក់ដោយអនុវត្តតាមការណែនាំ<br>- ប្រាប់បានពីសូរសំឡេង និងឈ្មោះវត្ថុផ្សេងៗដែលបាន គោះ និងសូរសំឡេងនានាក្នុងបរិស្ថាន។<br>**បំណិនសម្បទា**<br>- រៀបរូបភាព និងរៀបរាប់តាមដំណើររឿង<br>- ឆ្លើយតបនឹងសំណួរសាមញ្ញៗយ៉ាងតិច៤សំណួរ ឬលើសពីនេះ<br>- ធ្វើសកម្មភាពតាមការណែនាំ ដោយមានចលនា៤ ឬលើសពីនេះ | ៨ ម៉ |

| | | | |
|---|---|---|---|
| | | ទៅតាមដំណាក់ដូចជា៖ យកពែងនៅលើតុ ទៅដាក់កន្លែងលាង រួចមកអង្គុយទីនេះ និងទះដៃចំនួន ២ដង<br>- បង្ហាញបានពីសូរសំឡេង និងឈ្មោះរបស់វត្ថុផ្សេងៗដែលបានគោះ ដូចជា សៀវភៅ ឬស្សី ប្លាស្ទិច ដែក ការចាក់ទឹក ហែកក្រដាសជាដើម និងសូរសំឡេងនានាក្នុងបរិស្ថាន។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ស្តាប់ការនិទានរឿងដោយសប្បាយរីករាយ<br>- គោរពតាមការណែនាំដោយពេញចិត្ត។ | |
| **ការសន្ទនា** | សន្ទនាដោយប្រើពាក្យ ឬឃ្លាត្រូវតាមវ័យ(ភាសាបង្ហាញអារម្មណ៍ និងមនោសញ្ចេតនា) | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីព័ត៌មានផ្ទាល់ខ្លួន ឬព្រឹត្តិការណ៍ផ្សេងៗដែលបានជួបតាមលំដាប់លំដោយនៃសាច់រឿង<br>- ប្រាប់បានពីព័ត៌មានត្រឡប់ពីអ្នកដទៃតាមរយៈសិល្បៈ។<br>**បំណិនសម្បទា**<br>- រៀបរាប់ពីព័ត៌មានផ្ទាល់ខ្លួន ឬព្រឹត្តិការណ៍ផ្សេងៗ ដែលបានជួបតាមលំដាប់លំដោយនៃសាច់រឿងទៅមិត្តភក្តិ ឬមនុស្សធំ<br>- សួរសំណួរ និងទទួលព័ត៌មានត្រឡប់ពីអ្នកដទៃ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយក្នុងការសន្ទនាតាមការណែនាំ<br>- ឥរិយាបថសមរម្យ រង់ចាំវេននិយាយ និងចូលរួមក្នុងការសន្ទនា ។ | ៦ ម៉ |
| **ការប្រើពាក្យតាមវេយ្យាករណ៍** | ការយល់អំពីវាក្យស័ព្ទ ឃ្លា និងល្បះ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពាក្យទាក់ទងនឹងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ និងសកម្មភាពចាំបាច់មួយចំនួន<br>- ប្រាប់ពីពាក្យ ឃ្លា និងល្បះបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី ៥ ទៅ ៩ព្យាង្គ ឬលើសពីនេះ ។<br>**បំណិនសម្បទា**<br>- និយាយជាឃ្លា ល្បះ បានច្បាស់ ពីប្រធានបទអ្វីមួយដោយមិនចាកប្រធានបទ<br>- ប្រើពាក្យ ឬឃ្លា ឬល្បះទៅតាមស្ថានភាពមនុស្សធំដោយប្រើពាក្យដែលមានចំនួនពី ៥ ទៅ ៩ព្យាង្គ ឬលើសពីនេះដូចជា ៖ លោកតាពិសាបាយ ពុកខ្ញុំអញ្ជើញទៅស្រែ ជាដើម។ | ៦ ម៉ |

| | | | |
|---|---|---|---|
| | | **ចរិយាសម្បទា**<br>- មានទម្លាប់ប្រើពាក្យ ឃ្លា ល្បះខ្លីៗទៅតាមសកម្មភាពមួយចំនួនបានច្បាស់លាស់ និងត្រឹមត្រូវ ។ | |
| **ការប្រើពាក្យសម្ដីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង** | ទំនាក់ទំនងដោយប្រើពាក្យសម្ដី | **វិជ្ជាសម្បទា**<br>- ប្រាប់ពីសកម្មភាពនៅក្នុងសាច់រឿងឱ្យអ្នកដទៃស្ដាប់<br>- ប្រាប់បានពីសកម្មភាពដែលខ្លួនពេញចិត្តក្រោយពីស្ដាប់រឿងនិទានចប់ និងវិភាគតួអង្គ។<br>**បំណិនសម្បទា**<br>- និទានរឿងតាមរូបភាពឱ្យអ្នកដទៃស្ដាប់<br>- រៀបរាប់ពីសកម្មភាពដែលខ្លួនពេញចិត្តក្រោយពីស្ដាប់រឿងនិទានរួច និងឈានទៅវិភាគតួអង្គ។<br>**ចរិយាសម្បទា**<br>- ចូលចិត្តស្ដាប់រឿងនិទាន និងនិទានរឿងឱ្យមិត្តភក្ដិស្ដាប់ ។ | ៦ ម៉ |
| | ទំនាក់ទំនងដោយប្រើកាយវិការ និងនិមិត្តសញ្ញា | **វិជ្ជាសម្បទា**<br>- ប្រាប់បាននិមិត្តសញ្ញាសាធារណៈទៅអ្នកដទៃចំនួន៤ ដូចជាបន្ទប់ទឹកប្រុសនិងស្រី  សញ្ញាពេទ្យ សញ្ញាគ្រោះថ្នាក់ ជាដើម។<br>**បំណិនសម្បទា**<br>- បង្ហាញពីនិមិត្តសញ្ញាសាធារណៈទៅអ្នកដទៃចំនួន ៤ ដូចជាបន្ទប់ទឹកស្រី បន្ទប់ទឹកប្រុស  សញ្ញាពេទ្យ សញ្ញាគ្រោះថ្នាក់ ជាដើម។<br>**ចរិយាសម្បទា**<br>- ឈ្លាសវៃក្នុងការទំនាក់ទំនងរបស់ខ្លួន ដើម្បីបង្ហាញនិមិត្តសញ្ញា។ | ៦ ម៉ |
| | និមិត្តសញ្ញាតំណាងឱ្យមនុស្ស សត្វ ឬ វត្ថុនានា | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឈ្មោះមនុស្ស  សត្វ  វត្ថុ ឱ្យបានចំនួន ៤ តាមរយៈការធ្វើចលនាត្រាប់តាមនិមិត្តសញ្ញា។<br>**បំណិនសម្បទា**<br>- បង្ហាញនិមិត្តសញ្ញាមួយឱ្យកុមារធ្វើចលនាត្រាប់តាម និងប្រាប់ឈ្មោះមនុស្ស សត្វ ឬវត្ថុបានចំនួន ៤ ។<br>**ចរិយាសម្បទា**<br>- សម្ដែងនូវអារម្មណ៍សប្បាយរីករាយក្នុងការបង្ហាញ និងប្រាប់ឈ្មោះសត្វ វត្ថុ ដែលបានរកឃើញ។ | ៦ ម៉ |
| **ការស្គាល់តួអក្សរ** | ការប្រើញាណរបស់ខ្លួនដើម្បី អភិវឌ្ឍន៍បំណិនសមត្ថភាព | **វិជ្ជាសម្បទា**<br>-ប្រាប់ឈ្មោះសត្វ វត្ថុផ្សេងៗដោយស្ដាប់សំឡេង ឬសង្កេតកាយវិការ<br>-ប្រាប់បានពីរបៀបលេងល្បែងបុះសំណេរ។ | ១៥ ម៉ |

| | | | |
|---|---|---|---|
| | **ទាំង៦** | **បំណិនសម្បទា**<br>- បង្ហាញឈ្មោះសត្វ ឬវត្ថុផ្សេងៗ តាមការស្ដាប់សំឡេង ឬការសង្កេតកាយវិការ ចាប់ឬជ្រើសរើសកូនកាសរូបភាពមួយក្នុងចំណោមរូបភាពចំនួន ៤ រូបយកមកមើលរួចធ្វើកាយវិការ សំឡេង និងប្រាប់ឈ្មោះ<br>- លេងល្បែងបុរសំណេរដោយប្រើប្រាស់បំណិនសមត្ថភាពទាំង៦។<br>**ចរិយាសម្បទា**<br>- មានចំណូលចិត្ត និងសប្បាយរីករាយក្នុងការលេងល្បែង។ | |
| | **ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង និងកំណាព្យ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីទិសនៃសូរសំឡេង និងញែកសូរសំឡេងវត្ថុនានា<br>- ប្រាប់ពីចំណងជើង និងអត្ថន័យនៃកំណាព្យ<br>- ប្រាប់ពីឈ្មោះតួអក្សរងាយៗមួយចំនួន។<br>**បំណិនសម្បទា**<br>- ស្ដាប់និងបែងចែកសូរសំឡេងទូទៅដូចជា៖ សំឡេងសត្វ សំឡេងមនុស្ស និងដឹងពីប្រភពសំឡេង...<br>- សូត្រកំណាព្យត្រូវតាមវាក្យស័ព្ទ និងលំនាំបទ<br>- រកពាក្យបានតាមរយៈការផ្ដើមចេញពីតួអក្សរណាមួយ។<br>**ចរិយាសម្បទា**<br>- ចូលចិត្តសូត្រកំណាព្យ<br>- មានទំនុកចិត្តក្នុងការបង្កើតពាក្យផ្ដើមចេញពីតួអក្សរណាមួយ។ | **១២ ម៉** |
| | **ការយល់ដឹងអំពីបញ្ញត្តិនៃសំណេរ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបរៀបវត្ថុតូចៗលើតួអក្សរ និងស្រៈ<br>- ប្រាប់បានពីសំណេរតួអក្សរ និងស្រៈនៅក្នុងបរិស្ថានជុំវិញខ្លួន។<br>**បំណិនសម្បទា**<br>- រៀបវត្ថុតូចៗលើតួអក្សរ និងស្រៈ បានត្រឹមត្រូវតាមទិសនៃសំណេរ<br>- បង្ហាញបានពីទិសនៃសំណេរតួអក្សរ និងស្រៈ ។<br>**ចរិយាសម្បទា**<br>- សប្បាយរីករាយនឹងការបង្ហាញទម្រង់តួអក្សរនានា ។ | **១២ ម៉** |
| | **ការយល់ដឹងអំពីការអាន និងការប្រើប្រាស់ឯកសារសំណេរ** | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីរបៀបកាន់ និងបើកសៀវភៅរឿងនិទានដើម្បីអានពីទំព័រមុខរហូតដល់ទំព័រចុងក្រោយ មិនរំលងទំព័រ ។ | **៦ ម៉** |

| | | | |
|---|---|---|---|
| | ឬឯកសារផ្សេងៗ | **បំណិនសម្បទា**<br>- កាន់បើក និងអានសៀវភៅរឿងនិទានពីទំព័រមុខរហូតដល់ទំព័រចុងក្រោយបានត្រឹមត្រូវ<br>- បង្ហាញអាកប្បកិរិយាជក់ចិត្តក្នុងការអានរឿងនិទានដោយខ្លួនឯង។<br>**ចរិយាសម្បទា**<br>- មានចំណូលចិត្តអានរឿង និងចង់ចេះសរសេរអក្សរ។ | |
| | ការយល់ដឹងអំពីគោលការណ៍អក្ខរក្រម | **វិជ្ជាសម្បទា**<br>- ប្រាប់តួអក្សរក្នុងអក្ខរក្រមភាសាខ្មែរចំនួន៣០ និងស្រៈចំនួន៨។<br>**បំណិនសម្បទា**<br>- បង្ហាញពីលំដាប់អក្សរ(ព្យញ្ជនៈ)ក្នុងអក្ខរក្រមបានចំនួន ៣០ និងស្រៈចំនួន៨។<br>**ចរិយាសម្បទា**<br>- រីករាយនឹងការបង្ហាញលំដាប់តួអក្សរក្នុងអក្ខរក្រមភាសាខ្មែរ។ | ៣៨ ម៉ |
| **គូស និងសរសេរតួអក្សរ** | បំណិនសរសេរកាន់តែប្រសើរឡើង | **វិជ្ជាសម្បទា**<br>- ប្រាប់ឈ្មោះតួអក្សរតាមរាងអក្សរដែលមានស្នាមចុចៗ និងគំរូ<br>- ប្រាប់ឈ្មោះខ្លួនឯង ទាំងនាមត្រកូល និងនាមខ្លួន។<br>**បំណិនសម្បទា**<br>- សរសេរតួអក្សរ និងស្រៈបានតាមស្នាមចុច និងតាមគំរូ និងបញ្ចេញសូរត្រូវតាមតួអក្សរ។<br>- សរសេរឈ្មោះខ្លួនឯងតាមគំរូ ទាំងនាមត្រកូល និងនាមខ្លួន ។<br>**ចរិយាសម្បទា**<br>- មានទំនុកចិត្តនិងរីករាយក្នុងការសរសេរចម្លងអក្សរឈ្មោះខ្លួនឯង។ | ១៥ ម៉ |
| **ការយល់ដឹងពីភាសាដទៃ** | ការយល់ដឹងពីការប្រើភាសាខុសគ្នាសម្រាប់ប្រាស្រ័យទាក់ទងគ្នាក្រៅពីភាសាផ្ទាល់ខ្លួន | **វិជ្ជាសម្បទា**<br>- ប្រាប់បាននូវឈ្មោះភាសាផ្សេងដែលគេកំពុងនិយាយក្រៅពីភាសាកំណើតរបស់ខ្លួន។<br>**បំណិនសម្បទា**<br>- ឆ្លើយតបបានទៅនឹងការណែនាំដែលប្រាប់ជាភាសាផ្សេងក្រៅពីភាសាកំណើតរបស់ខ្លួន<br>- រៀបរាប់បាននូវពាក្យ និងឃ្លាងាយៗជាភាសាផ្សេងក្រៅពីភាសាកំណើតរបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- មិនរើសអើងចំពោះភាសា និងជាតិដទៃ ។ | ៤ ម៉ |

## ៨- ឯកសារយោង


១- ក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦

២- សៀវភៅកម្មវិធីសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ ផ្នែកមត្តេយ្យសិក្សារដ្ឋ

៣- ស្តង់ដាសិក្សាសម្រាប់កុមារអាយុ៣ឆ្នាំដល់៥ឆ្នាំ របស់ក្រសួងអប់រំ យុវជន និងកីឡា

៤- កម្មវិធីអប់រំកុមារក្នុងប្រទេសជប៉ុន របស់ក្រុមការងារកម្ពុជា ( TENRYU – KOHSEIKAI . JAPAN )

៥- របាយការណ៍ចាប់ផ្តើមសម្រាប់ការកែលម្អកម្មវិធីសិក្សាផ្នែកមត្តេយ្យសិក្សានៅកម្ពុជា (បទបង្ហាញ របស់បណ្ឌិត **Chong Har Tshin Association for Early Childhood Educators (Singapore)** )

៦- អភិក្រមបែបស្ថាបនា **High Scope** (បទបង្ហាញរបស់បណ្ឌិត **Chong Har Tshin Association for Early Childhood Educators (Singapore)** )

៧- វិធីសាស្ត្រផ្សេងៗសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃ (បទបង្ហាញរបស់បណ្ឌិត **Chong Har Tshin Association for Early Childhood Educators (Singapore)** )

៨- Key Concepts for Understanding Curriculum (Colin j. Marsh) , Fourth edition. 2013

៩- Education in Singapore .

## ៩- បញ្ជីឈ្មោះគណៈកម្មការ

### I. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ ជួន | ណារ៉ុន |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត | ប៊ុនរឿន |
| ៣- លោកជំទាវ | គឹម | សេដ្ឋានី |
| ៤- លោកជំទាវ | ឃុន | រចនា |
| ៥- ឯកឧត្តម | ពុត | សាមិត្ត |
| ៦- ឯកឧត្តម | ឡេ្យ | ឆវណ្ណា |
| ៧- លោកបណ្ឌិត | ម៉ុក | សារ៉ុម |
| ៨- ឯកឧត្តម | ប្រាក់ | កុសល |

### II. គណៈកម្មការនិពន្ធ

| | | |
|---|---|---|
| ១- ឯកឧត្តម | ប្រាក់ | កុសល |
| ២- លោក | យិន | ធី |
| ៣-លោកស្រី | ផ្លុង | មុនីកុសល |
| ៤-លោក | ឈួន | ប៊ុនឈឿន |
| ៥- លោកស្រី | សេង | ហ្សានីន |
| ៦- លោកស្រី | អ៊ុម | សុផានី |
| ៧- លោកស្រី | រស់ | សេដ្ឋា |
| ៨- លោកស្រី | សុខ | សោភា |
| ៩- លោកស្រី | រ័ត្ន | ម៉ារិន |
| ១០-លោក | សុក | សុខុម |
| ១១-លោកស្រី | សេង | សុវណ្ណា |
| ១២-លោកស្រី | កែ | វ៉ា |
| ១៣-លោកស្រី | វ៉ែន | វ៉ាន់ថា |
| ១៤-លោកស្រី | ង៉ុយ | គឹមច័ន្ទដាវី |
| ១៥-លោកស្រី | មៀច | ច័ន្ទស៊ីថា |

### III. គណៈកម្មការពិនិត្យ

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ ជួន | ណារ៉ុន |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត | ប៊ុនរឿន |
| ៣- លោកជំទាវ | គឹម | សេដ្ឋានី |
| ៤- ឯកឧត្តម | ពុត | សាមិត្ត |
| ៥- ឯកឧត្តម | ឡេ្យ | ឆវណ្ណា |
| ៦- លោកបណ្ឌិត | ម៉ុក | សារ៉ុម |
| ៧- ឯកឧត្តម | ប្រាក់ | កុសល |
| ៨- លោក | ឈុន | វ៉ាមី |
| ៩- លោកស្រី | ម៉ៅ | ណាវី |
| ១០- លោក | មួង | ចាន់ទូច |

១១- តំណាងធនាគារពិភពលោក

១២- តំណាងអង្គការ UNICEF

១៣-បណ្ឌិត Chong Har Tshin Association for Early Childhood Educators (Singapore)

១៤-តំណាងអង្គការ SVA

១៥-តំណាងអង្គការ Plan International

### IV. បច្ចេកទេសកុំព្យូទ័រ

| | | |
|---|---|---|
| ១- លោក | ឈួន | ប៊ុនឈឿន |
| ២-លោក | យិន | ធី |
| ៣- លោក | ប៉ូវ | វី |
| ៤- លោក | សុក | សុខុម |
| ៥- លោក | លឹម | សិរីវុឌ្ឍី |
| ៦- លោក | ណាយសុចិត្រា | |

បោះពុម្ព លើកទី២
ប្រើប្រាស់ថវិកាកម្មវិធីឆ្នាំ២០២០
របស់អង្គភាពថវិកានាយកដ្ឋានអប់រំកុមារតូច

បោះពុម្ព លើកទី២
ប្រើប្រាស់ថវិកាកម្មវិធីឆ្នាំ២០២០
របស់អង្គភាពថវិកានាយកដ្ឋានអប់រំកុមារតូច